00323256

D158/5/1/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / MAY / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Ly

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ-២៥)២១

**ដាក់ទៅ:** អង្គបុរេជំនុំជម្រះ

**ថ្ងៃដាក់:** ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០០៩

**ភាគីដាក់:** សហមេធាវី នួន ជា

**ភាសាដើម:** អង់គ្លេស(ឯកសារដើម) និង ភាសាខ្មែរ(អត្ថបទបកប្រែ)

**ប្រភេទឯកសារដែលស្នើឡើង**
**ដោយភាគីដាក់ឯកសារ:** សារធារណ:

---

## បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើលើកទី ១១ ស្នើសុំបំពេញកិច្ចស៊ើបសួរ

---

**ដាក់ឯកសារដោយ៖**

**សហមេធាវីការពារលោក នួន ជា**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

លោក ម៉ម ចាន់ណា

លោក Andrew IANUZZI

**ជំនួយការដោយ:**

កញ្ញា Shona GRUNDy

កញ្ញា JESSICA PEAKE

**ចែកចាយជូន៖**

**ចៅក្រមអង្គបុរេជំនុំជម្រះ**

ប្រាក់ គឹមសាន

លោក ហួត វុទ្ធី

លោក Rowan DOWNING

លោក ន័យ ថុល

លោកស្រី Katinka LAHUIS

លោក ប៉ែន ពេជ្រសាលី

**សហព្រះរាជអាជ្ញា:**

អ្នកស្រី ជា លាង

លោក Robert PETI

លោក ANEES AHMED

**ក្រុមការពារទាំងអស់**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / 05 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Ly

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៧៣ ៧៤ និងវិធាន ៧៥ នៃវិធានផ្ទៃក្នុង សហមេធាវីរបស់ជនត្រូវចោទ នួន ជា (ហៅថា "មេធាវីការពារ") សូមដាក់បណ្តឹងឧទ្ធរណ៍នេះទៅអង្គបុរេជំនុំជម្រះ (ហៅថា "អបជ") ប្រឆាំងនឹង "ដីកាសម្រេចលើសំណើលើកទី ១១ ស្នើសុំបំពេញកិច្ចស៊ើបសួរ"(ហៅថា"ដីកាសម្រេច")[1] ចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេត(ហៅថា"ក.ស.ច.ស")។ សម្រាប់មូលហេតុលើកឡើងនៅខាងក្រោម មេធាវីការពារសូមលើកឡើងថា: (i) បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន, (ii) ក.ស.ច.ស មានអំណាចជាប់មកជាមួយដើម្បីផ្តល់ដំណោះស្រាយដែលបានស្នើសុំ, (iii) សំណើសុំបំពេញកិច្ចស៊ើបសួរនេះ ត្រូវបានគាំទ្រដោយអង្គហេតុគ្រាប់គ្រាន់ និង (iv) វាជាការឥតប្រយោជន៍ក្នុងការរង់ចាំដំណោះស្រាយលើបញ្ហានេះ ដោយរាជរដ្ឋាភិបាលកម្ពុជា និង/ឬ អង្គការសហប្រជាជាតិ។

## II. ប្រវត្តិនីតិវិធី

2. មេធាវីការពារបានដាក់ "សំណើលើកទី ១១ ស្នើសុំបំពេញកិច្ចស៊ើបសួររបស់ខ្លួន" (ហៅថា "សំណើ") នៅថ្ងៃទី ២៧ មីនា ២០០៩[2] ស្នើសុំឱ្យ "ក.ស.ច.ស ទទួលពីអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលកម្ពុជា និង/ឬអង្គការនានា ឬបុគ្គលណាមួយ នូវលទ្ធផល [នៃការស៊ើបអង្កេតរបស់ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុង(ហៅថា "OIOS")] និងលិខិតឆ្លើយឆ្លងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងទៅនឹងការស៊ើបអង្កេតរបស់ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុង និងព័ត៌មានទាំងឡាយ ដែលលើកឡើងពីអំពើពុករលួយជាស្ថាប័នដែលមានជាប្រព័ន្ធរៀបចំចាត់ចែងនៅ អ.វ.ត.ក[3]

---

[1] ឯកសារលេខ D-158/5 ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៩ ។

[2] ឯកសារលេខ D-158 ។

[3] ឯកសារលេខ D-158 កថាខណ្ឌ ២២ ។

បន្ថែមពីនេះលើ មេធាវីការពារបានអញ្ជើញ ក.ស.ច.ស ឲ្យបំពេញកិច្ចស៊ើបសួរផ្នែករដ្ឋបាលទៅលើការចោទប្រកាន់ពីអំពើពុករលួយ ដែលមិនទាន់បានដោះស្រាយនៅក្នុងសាលាក្តីនេះនៅឡើយនោះ[4] ។

3. មេធាវីការពាររបស់ជនត្រូវចោទ អៀង សារី អៀង ធីរិទ្ធ និង ខៀវ សំផន បានដាក់ញត្តិដាច់ដោយឡែកពីគ្នា ដើម្បីគាំទ្រដល់សំណើនេះ[5]។ ការិយាល័យសហព្រះរាជអាជ្ញា (ហៅថា "ក.ស.ព") មិនបានឆ្លើយតបទៅនឹងសំណើនេះ ឬ សំណើជាបន្តបន្ទាប់របស់មេធាវីការពារក្តីនោះឡើយ ។

4. ក.ស.ច.ស កាលពីថ្ងៃទី ៣ មេសា ២០០៩ បានបដិសេធលើសំណើ ដោយសន្និដ្ឋានថា: (i) ខ្លួនពុំមានអំណាចផ្តល់ដំណោះស្រាយដែលបានស្វែងរកនោះទេ[6], (ii) "ផលប៉ះពាល់អវិជ្ជមាននៃអំពើពុករលួយគឺជាការប្រមើលមើល[7] ហើយបច្ចុប្បន្ននេះ បញ្ហានេះកំពុងត្រូវបានដោះស្រាយដោយរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ[8] ។

---

[4] ឯកសារលេខ D-158 កថាខណ្ឌ ២២ ។

[5] ឯកសារលេខ D-158/2 "ញត្តិរបស់ អៀង សារី ដើម្បីចូលរួម និង គាំទ្រសំណើលើកទី ១១ ស្នើសុំបំពេញកិច្ចស៊ើបសួររបស់ នួន ជា ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩។ ឯកសារលេខ D-158/3 "ញត្តិគាំទ្រដល់សំណើលើកទី ១១ របស់ នួន ជា ស្នើសុំបំពេញកិច្ចស៊ើបសួរដើម្បីឲ្យមានការបង្ហាញរបាយការណ៍របស់ OIOS និង ឯកសារពាក់ព័ន្ធ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៩ និង ឯកសារលេខ D-158/4 [FR] ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៩ ។

[6] ដីកាសម្រេច កថាខណ្ឌ ៨ ("អំណាចរបស់សហចៅក្រមស៊ើបអង្កេតដើម្បីបំពេញកិច្ចស៊ើបសួរណាមួយ ដែលមានប្រយោជន៍ដល់ការបង្ហាញការពិត" ត្រូវអនុវត្តនៅក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន ដែលកំណត់ដោយមាត្រា ២ នៃច្បាប់បង្កើត អ.វ.ត.ក ដែលកំណត់អំពីយុត្តាធិការលើបុគ្គល បទល្មើស និង យុត្តាធិការពេលវេលារបស់តុលាការនេះ, កថាខណ្ឌ ៩ (វិធាន ៥៥(២) នៃវិធានផ្ទៃក្នុងអនុញ្ញាតឲ្យ ក.ស.ច.ស "ស៊ើបសួរតែទៅលើអង្គហេតុដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដោយព្រះរាជអាជ្ញា តែប៉ុណ្ណោះ), កថាខណ្ឌ ១០ (អំណាចរបស់ ក.ស.ច.ស មិនក្តោបក្តាប់ទៅដល់សមត្ថកិច្ចក្នុងការបង្ហាញការពិត "អំពីតុលាការនេះ" ដូចតាមការចង់បានរបស់មេធាវីការពារក្តីនោះទេ វាគឺជាបញ្ហាដែលមិនពាក់ព័ន្ធទាល់តែសោះជាមួយនឹងអង្គហេតុ ដែលជាកម្មវត្ថុនៃកិច្ចស៊ើបសួរបច្ចុប្បន្ននោះទេ) និង កថាខណ្ឌ ១១ (ការទទួលយកសំណើនេះ គឺជាការប្រើប្រាស់អំណាចក្នុងផ្លូវខុស ពីព្រោះអង្គហេតុទាំងអស់នោះមិនឋិតនៅក្នុងសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ដោយអនុវត្តលោមទៅតាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នោះទេ)។

[7] សូមមើលដីកាសម្រេច កថាខណ្ឌ ១២ (ពិតណាស់ សហចៅក្រមស៊ើបអង្កេតត្រូវធានាថា គ្រប់ចំណុចនៃនីតិវិធីដែលកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននៅក្នុង អ.វ.ត.ក មិនត្រូវបានគេស្តីបន្ទោស ជាពិសេសចំពោះរឿងដែលថា គ្រប់ទង្វើដែលជាការចូលជ្រៀត

## III. សាវតារអង្គហេតុ

5. មេធាវីការពារសូមដាក់បញ្ចូលសំណើដែលមាននៅក្នុងកថាខណ្ឌទី ៤ រហូតដល់កថាខណ្ឌទី ១២ នៃ សំណើលើកទី ១១ ស្នើសុំបំពេញកិច្ចស៊ើបសួរនេះ ។ ចាប់តាំងពីការដាក់ឯកសារនោះមក ការវិវឌ្ឍន៍ពាក់ព័ន្ធបន្ថែមបានលាតត្រដាងនូវ:

ក. កាលពីខែមីនា ឆ្នាំ ២០០៩ អង្គការលើកលែងទោសអន្តរជាតិបានប្រកាសថា ការចោទប្រកាន់ពីអំពើពុករលួយដែលមិនទាន់ដោះស្រាយ "បានបង្កឲ្យមានមន្ទិលសង្ស័យជាក់លាក់ទៅលើ សមត្ថភាព ឯករាជ្យភាព និង អនាគតិរបស់ [អ.វ.ត.ក]" ហើយអង្គការនេះបានកត់សំគាល់ថា "ការខកខានរបស់រដ្ឋាភិបាល និង អង្គការសហប្រជាជាតិក្នុងការឆ្លើយតបចំពោះអំពើពុករលួយប្រកបដោយតម្លាភាព នឹងបង្កការគំរាមកំហែងដល់កិត្តិនាមរបស់ស្ថាប័នកាន់តែខ្លាំង [9]។

ខ. ចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង អ្នកស្រី Silvia Cartwright កាលពីថ្ងទី ២៧ ខែ មីនា ២០០៩ បានផ្តល់នូវការវាយតំលៃខ្លី តែច្បាស់លើបញ្ហានេះ ដោយសន្និដ្ឋានថា ប្រសិនបើតុលាការនេះធ្វើសម្បទានជ្រុលពេក នោះ "ចៅក្រម [អន្តរជាតិ] មួយចំនួននឹងវេចបង្វិតទៅផ្ទះ[10]។

---

ជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញទាំងអស់ ត្រូវបានដាក់ទណ្ឌកម្ម និងបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច ដោយអនុលោមទៅតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង។ ផ្ទុយទៅវិញ គ្មានអ្វីដែលអាចបញ្ជាក់បានអំពីអត្ថិភាពនៃទង្វើបែបនេះទេ សំណើសុំនោះ គ្រាន់តែលើកឡើងអំពីការប្រមើលមើលឃើញអំពីផលពិបាកដ៏អាក្រក់ជាយថាហេតុណាមួយ ប្រសិនបើមានអំពើពុករលួយគ្រប់រូបភាពកើតឡើង ចំពោះដំណើរការនីតិវិធីតុលាការតែប៉ុណ្ណោះ) ។

[8] សូមមើលដីកាសម្រេច កថាខណ្ឌ ១៣ (ជាចុងក្រោយ សំណើសុំឲ្យមានការស៊ើបសួររដ្ឋបាលលើបញ្ហានេះពីសំណាក់សហចៅក្រមគឺជារឿងឥតប្រយោជន៍ ព្រោះថាអាជ្ញាធរកម្ពុជា និង អង្គការសហប្រជាជាតិជាអ្នកមានសមត្ថកិច្ចលើបញ្ហានេះ ហើយមានគ្រប់ព័ត៌មានទាំងអស់ ដែលបានលើកឡើងនៅក្នុងសំណើនេះ។

[9] អត្ថបទរបស់អង្គការលើកលែងទោសអន្តរជាតិ ក្រោមចំណងជើងថា "កម្ពុជា: ការកាត់សេចក្តីលើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមដែលបានប្រព្រឹត្តអស់រយៈពេល ៣០ ឆ្នាំមកហើយ", AI Index: ASA 23/03/2009 ទំព័រ ៣ ។

[10] NZPA "ការងារដ៏លំបាកនៅខាងមុខសម្រាប់ចៅក្រមជាតិញូហ្សេឡែន អ្នកស្រី Dame Silvia Cartwright" ចុះថ្ងៃទី ២៧ មីនា ២០០៩ ។

គ. មានសេចក្តីរាយការណ៍កាលពីថ្ងៃទី១ មេសា ២០០៩ ថា "បុគ្គលិកពីររូបនៃការិយាល័យរដ្ឋបាលរបស់តុលាការ បាននិយាយប្រាប់ទូរទស្សន៍ CNN អំពីគ្រោងការកាត់ប្រាក់បៀវត្សដែលកំពុងបន្ត ពាក់ព័ន្ធជាមួយបុគ្គលិកកម្ពុជា ដែលអ្នកផ្តល់ព័ត៌មានម្នាក់បានប៉ាន់ប្រមាណថាមានប្រាក់ពី ៣០.០០០ ដុល្លា ទៅ ៤០.០០០ ដុល្លា ក្នុងមួយខែឯណោះ។ "ពួកគេត្រូវបង់ប្រាក់បៀវត្សក្នុងចំនួនជាក់លាក់មួយ ក្នុងភាគរយជាក់លាក់មួយ[...]។ ហេតុដូច្នេះ ជារៀងរាល់ខែពួកគេដាក់លុយនៅក្នុងស្រោមសំបុត្រ ហើយប្រគល់ស្រោមសំបុត្រនេះទៅឲ្យ...។ នៅផ្នែកនិមួយៗមានមនុស្សម្នាក់ដើរប្រមូលប្រាក់...ដែលជាប្រាក់សុទ្ធ ជាលុយដុល្លាអាមេរិក[11]។ របាយការណ៍ដដែលបានកត់សំគាល់ថា បញ្ហានេះ "កំពុងត្រូវបានការស៊ើបអង្កេតដោយ [OIOS] ដែលកិច្ចការនេះ គឺជាការសម្ងាត់ ហើយលទ្ធផលនៃការស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិ នឹងដាក់ជូនរដ្ឋាភិបាលម្ពុជា ដើម្បីមានវិធានការបន្ត[12]។

ឃ. កាលពីថ្ងៃទី ១ មេសា ២០០៩ មានអត្ថបទសារព័ត៌មានមួយដោយអ្នកសារព័ត៌មានម្នាក់ដែលមានមូលដ្ឋាននៅទីក្រុងភ្នំពេញ (ដែលកំពុងយកព័ត៌មានពីអំពើពុករលួយអស់រយៈពេលពីរឆ្នាំមកហើយ) បានបោះពុម្ពផ្សាយនៅលើ*ទិនានុប្បវត្តិ Wall Street Journal* ។ ជាថ្មីម្តងទៀតដូចដែលបានកើតឡើងកាលពីដើមឆ្នាំ ២០០៧[13] មានការសន្និដ្ឋានថា ចៅក្រមកម្ពុជាអាចពាក់ព័ន្ធជាមួយគ្រោងការដែលត្រូវបានចោទប្រកាន់: "នៅចំចំណុចកណ្តាលនៃការចោទប្រកាន់ពីអំពើពុករលួយ គឺជាការចោទប្រកាន់តែមួយគត់: បុគ្គលិកកម្ពុជា រួមទាំងចៅក្រមមួយចំនួនផងដែរ ត្រូវបានផ្តល់នូវតួនាទីដែលមានប្រាក់កម្រៃខ្ពស់នៅតុលាការ ដោយផ្អែកលើមូលដ្ឋាន

---

[11] Dan River, *CNN,* "តុលាការខ្មែរក្រហមកម្ពុជាស៊ើបអង្កេតអំពើពុករលួយ" ចុះថ្ងៃទី១ មេសា ២០០៩ ។

[12] Dan River, *CNN,* "តុលាការខ្មែរក្រហមកម្ពុជាស៊ើបអង្កេតអំពើពុករលួយ" ចុះថ្ងៃទី១ មេសា ២០០៩ ។

[13] សូមមើលសំណើ កថាខណ្ឌ ៤(ក) ។

ដែលថា ពួកគេត្រូវបង់ប្រាក់មួយផ្នែកនៃប្រាក់បៀវត្សរបស់ពួកគេជារៀងរាល់ខែទៅឱ្យមន្ត្រីរដ្ឋាភិបាលដែលផ្តល់ការងារឱ្យពួកគេ[14]។

ង. មានសេចក្តីរាយការណ៍នៅថ្ងៃទី ២ មេសា ២០០៩ ថា "លោក ស៊ាន វិសុទ្ធ [...] បានធ្វើដំណើរទៅទីស្នាក់ការធំរបស់អង្គការសហប្រជាជាតិនៅទីក្រុងញូយ៉ក ចំនួនពីរលើកកាលពីដំណាច់ឆ្នាំ ២០០៨ "ដើម្បីចូលរួមកិច្ចពិភាក្សា"[15]។

ច. ទស្សនាវដ្តី *The economist* កាលពីថ្ងៃទី ៤ មេសា ២០០៩ បានរាយការណ៍ថា មានបុគ្គលិកអនាមិកចំនួនបីនាក់របស់តុលាការ "បានចោទប្រកាន់លោក ស៊ាន វិសុទ្ធ [...] ពីការប្រមូលប្រាក់ពីបុគ្គលិកកម្ពុជានៅក្នុងនាយកដ្ឋានរបស់គាត់ រួមទាំងបុគ្គលិកតុលាការ និងជំនួយការផ្នែកច្បាប់ជនជាតិកម្ពុជានៅក្នុងការិយាល័យ [ក.ស.ច.ស និងក.ស.ព]។ ពួកគេត្រូវបានប្រាប់ថា ប្រាក់មួយចំនួនត្រូវផ្តល់ទៅឱ្យលោកឧបនាយករដ្ឋមន្ត្រី សុខ អាន"[16]។ នៅក្នុងអត្ថបទដដែល លោក ខៀវ កាញារីទ្ធ អ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ថា "ការត្រួតពិនិត្យលើអំពើពុករលួយដោយអង្គការសហប្រជាជាតិ បានចុកចាំឈ្មោះ [លោក ស៊ាន វិសុទ្ធ] និង បានស្នើឱ្យដកមុខដំណែងរបស់គាត់ទៀតផង"[17]។ តាមការពន្យល់របស់តុលាការទាក់ទងនឹងអវត្តមានដ៏យូររបស់គាត់ គឺថា លោក ស៊ាន វិសុទ្ធ ឈប់សំរាកដោយមានជំងឺ នោះ"គ្រាន់តែជាការសុំទោសផ្នែកនយោបាយតែប៉ុណ្ណោះ" លោក ខៀវ កាញារីទ្ធ បន្ថែម[18]។ នៅក្នុងអត្ថបទដដែលនេះផងដែរ សហចៅក្រមស៊ើបអង្កេត Marcel lemond ដែលស្និទស្នាលជាមួយបរិយាកាសតុលាការដែលប្រកបដោយការសម្បទាននៅ អ.វ.ត.កៈ

---

[14] លោក Cat Barton, *The wall street Journal* "ភាពច្របូកច្របល់នៅតុលាការ" ចុះថ្ងៃទី ១ មេសា ២០០៩ ។

[15] លោក សុខ ខេមរា វិទ្យុសម្លេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ចុះថ្ងៃទី ២ មេសា ឆ្នាំ ២០០៩ ។

[16] ទស្សនាវដ្តី *The economist [...], [...],* "ខ្មែរក្រហម និង យុត្តិធម៌ តុលាការកំពុងជំនុំជម្រះ" ចុះថ្ងៃទី ៤ មេសា ០៩ ទំព័រ ៣១ ។

[17] ទស្សនាវដ្តី *The economist [...], [...],* ទំព័រ ៣១ ។

[18] ទស្សនាវដ្តី *The economist [...], [...],* ទំព័រ ៣១ ។

បានថ្លែងថា "វាមានភាពងាយស្រួលដើម្បីធ្វើជាចៅក្រមអន្តរជាតិដ៏បរិសុទ្ធម្នាក់នៅក្នុងតុលាការអន្តរជាតិដ៏បរិសុទ្ធមួយដែលនៅឆ្ងាយពីកម្ពុជា *ឆ្ងាយពីបរិយាកាសដ៏ពុករលួយនេះ*"[19]។

ឆ. នៅក្នុងអត្ថបទរបស់ខ្លួនចេញផ្សាយសម្រាប់ខែមីនា/មេសា ២០០៩ ទស្សនាវដ្ដី *Foreign Affairs* បានរាយការណ៍ថា ចាប់តាំងពីបានក្ដោបក្ដាប់អំណាចនៅឆ្នាំ ១៩៩៧ មក រដ្ឋាភិបាលលោក ហ៊ុន សែន កំពុង "ជំរុញប្រព័ន្ធពុករលួយយ៉ាងទូលំទូលាយមួយ ហើយស្របពេលជាមួយគ្នានេះ កំពុងតែធ្វើមិនដឹងមិនឮចំពោះការតវ៉ា ឬ បណ្ដឹងនានាពីបណ្ដាលអង្គការ និង រដ្ឋាភិបាលនានានៅជុំវិញពិភពលោក"[20]។ អនុលោមទៅតាមអត្ថបទនេះ ការសិក្សាយ៉ាងទូទាំទូលាយដែលគាំទ្រផ្នែកហិរញ្ញវត្ថុដោយសហរដ្ឋអាមេរិក ដែលបានផ្សព្វផ្សាយនៅឆ្នាំ ២០០៤ និង ២០០៥ "បង្ហាញលំអិតថា មន្ត្រីរដ្ឋាភិបាលកម្ពុជាលួចប្រាក់ក្នុងរវាង ៣០០ លានដុល្លា និង ៥០០ លានដុល្លាក្នុងមួយឆ្នាំ (សឹងតែជារៀងរាល់ឆ្នាំ ថវិកាប្រចាំឆ្នាំរបស់រដ្ឋ គឺប្រហែលមួយពាន់លានដុល្លា")[21]។ អ្នកនិពន្ធបានកត់សំគាល់ថា ការចោទប្រកាន់ពីអំពើពុករលួយដែលមិនទាន់ដោះស្រាយនៅ អ.វ.ត.ក "បានធ្វើឲ្យមន្ត្រីអង្គការសហប្រជាជាតិក្ដៅក្រហាយក្នុងចិត្ត ប៉ុន្តែ បានធ្វើឲ្យមានការភ្ញាក់ផ្អើលតិចតួចក្នុងចំណោមប្រជាជនកម្ពុជា។ ជាចុងក្រោយ ពួកគេសិក្សាពីអំពើពុករលួយដោយផ្ទាល់ ដោយចាប់តាំងពីថ្នាក់ទី១មកម្លេះ"[22]។ អត្ថបទដដែលបានដកស្រង់សំដីលោក អ៊ុក សេរីសូភ័ក្រ អ្នកប្រឹក្សាពិគ្រោះផ្នែកនយោបាយដ៏សំខាន់ម្នាក់នៅកម្ពុជា: "មនុស្សគ្រប់រូប គឺពុករលួយ [...]។ វាគឺជារបៀបរបបរស់នៅនៅទីនេះ"[23]។

---

[19] ទស្សនាវដ្ដី *The economist* ទំព័រ ៣២ (បញ្ជាក់បន្ថែម) ។

[20] Joel Brinkley, Foreign Affairs, "ពុះពារដើម្បីលុបបំបាត់កេរ្តិ៍មរតករបស់ខ្មែរក្រហមៈ រដ្ឋាភិបាលរបស់ឯកឧត្តមកំពុងបំផ្លាញជាតិ, ចុះថ្ងៃទី ១៦ មេសា ២០០៩ ទំព័រ ១១២ ។

[21] ដូចខាងលើ ទំព័រ ១១៨ ។

[22] ដូចខាងលើ ទំព័រ ១១៥ ។

[23] ដូចខាងលើ ទំព័រ ១១៨ ។

ជ. សហព្រះរាជអាជ្ញាអន្តរជាតិលោក Robert Petit កាលពីថ្ងៃទី ២៤ មេសា ២០០៩ ជាចុងក្រោយបានបន្ថែមសម្តែងរបស់គាត់ចំពោះការតិទៀនពីអំពើពុករលួយថា: "អំពើពុករលួយត្រូវតែបញ្ឈប់ ធ្វើយ៉ាងហេតុដូច្នេះ វាឈប់មានចំណែកជាមួយកិច្ចការសំខាន់ៗជាច្រើនទៀតរបស់តុលការ តទៅទៀតហើយ។ ពាក់កណ្តាលនៃកិច្ចការសំខាន់ៗរបស់តុលាការ គឺអំពីបញ្ហាដែលពួកគេបដិសេធមិនដោះស្រាយ។ វាបានគំរាមកំហែងដល់និរន្តភាពរបស់តុលាការ។ វាគឺជាបញ្ហាដ៏ពិតៗ[24]។

ឈ. ទាក់ទងនឹងការចរចារស្តីពីការប្រឆាំងនឹងអំពើពុករលួយដែលកំពុងកើតឡើង រវាងរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ "លោក ហ៊ុន សែន ថ្លែងថា គាត់បានបញ្ជាលោក សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាឧបនាយករដ្ឋមន្ត្រី ប្អូនដង្ហូចមកហើយថា កុំឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងបន្ថែមទៀត ទាក់ទងនឹង អ.វ.ត.ក"[25]។ ទោះជាយ៉ាងណាក៏ដោយ លោក Peter Taksoe-Jensen ឧបការីរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកកិច្ចការច្បាប់ បានមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី ៦ ខែមេសា ២០០៩ ដើម្បីចរចារនៅជុំទី៣[26]។ លោក Peter Taksoe-Jensen បានលើកឡើងថា គាត់នឹងមិនលើមកពិភាក្សាអំពីបញ្ហានៃការរកឃើញរបស់ OIOS ជាមួយសមាសភាគីរដ្ឋាភិបាលរបស់គាត់ឡើយ[27] ប៉ុន្តែ លោកបានកត់សំគាល់ថា "នៅពេលនេះ អង្គការសហប្រជាជាតិ

---

[24] អត្ថបទរបស់ Asia Sentinel, "ការជំនុំជម្រះលើពួកគេខ្មែរក្រហមទទួលរងនូវការគំរាគកំហែង" ចុះថ្ងៃទី ២៤ មេសា ២០០៩ ។

[25] Douglas Gillison, ព្រឹត្តិប័ត្រសារព័ត៌មានដឹខែមបូដាលី "មិនមានការចោទប្រកាន់ខ្មែរក្រហមបន្ថែមទៀតទេ, លោក ហ៊ុន សែន និយាយ" ចុះថ្ងៃទី ១ មេសា ២០០៩ ទំព័រ ២ ។

[26] Douglas Gillison, ព្រឹត្តិប័ត្រសារព័ត៌មានដឹខែមបូដាលី "អង្គការសហប្រជាជាតិចរចារពីយន្តការប្រឆាំងនឹងអំពើពុករលួយនៅ អ.វ.ត.ក ចុះថ្ងៃទី ៦ មេសា ២០០៩ ទំព័រ ៣២។ សូមមើលផងដែរ អត្ថបទរបស់លោក សុខ ខេមរា វិទ្យុសម្លេងសហរដ្ឋអាមេរិកជាភាសាខ្មែរ "មន្ត្រីកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិមកដល់ ដើម្បីធ្វើការចរចារថែមទៀត ចុះថ្ងៃទី ៦ មេសា ឆ្នាំ ២០០៩

[27] Geogia Wilkins ព្រឹត្តិប័ត្រសារព័ត៌មានភ្នំពេញប៉ុស "ការស៊ើបអង្កេតលើអំពើពុករលួយនៅសាលាក្តីខ្មែរក្រហមមិនដាក់នៅក្នុងរបៀបវារៈនៃការចរចារទេ" ចុះថ្ងៃទី ៦ មេសា ២០០៩ ទំព័រ ២ ។

កំពុងធ្វើចំណាត់ការ [...] លើសំណើរបស់ក្រុមអ្នកច្បាប់របស់ នួន ជា ដែលបានស្នើសុំឱ្យលាតត្រដាងការរកឃើញដ៏ចំរូងចំរាស់នេះ"[28]។ កិច្ចពិភាក្សាបានឈានចូលដល់ថ្ងៃទី៣ ដែលមិនបានគ្រោងទុក ជាទីបំផុត ភាគីនៃកិច្ចចរចារបានឈានទៅដល់ភាពទាល់ច្រកមួយ[29]។ ជាចុងក្រោយ ពុំមានកិច្ចព្រមព្រៀងណាមួយត្រូវបានចុះហត្ថលេខានោះឡើយ ហើយ លោក Peter Taksoe-Jensen "បាននិយាយថា អង្គការសហប្រជាជាតិនឹងពុំមានការពិភាក្សាអំពីយន្តការរាយការណ៍អំពើពុករលួយនៅតុលាការ តទៅទៀតនោះទេ[30]។ ទោះបីជាកិច្ចចរចារនេះបរាជ័យក៏ដោយ ក៏មានការប្រកាសថា "អង្គការសហប្រជាជាតិបន្តជឿជាក់ថា តុលាការនឹងឆ្លើយតបបាននូវគោលការណ៍នៃការជម្រះក្តីប្រកបដោយយុត្តិធម៌"[31]។

ញ. សេចក្តីថ្លែងការណ៍រួមចេញនៅថ្ងៃទី ១៧ មេសា ២០០៨ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និង គណៈកម្មាធិការសិទ្ធិមនុស្សអាស៊ានសង្ខេបយ៉ាងហ្មត់ចត់ពីភាពគ្រោះថ្នាក់ ដែលបង្កឡើងដោយបញ្ហាដែលមិនទាន់ដោះស្រាយ: "អំពើពុករលួយបង្ហាញនូវសមាសភាពនៃការត្រួតត្រាពីខាងក្រៅមួយ ដែលប៉ះពាល់ដល់ឯករាជ្យភាពរបស់តុលាការ និង ការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។ បើសិនជាមនុស្សម្នាក់បង់ប្រាក់សងគុណឲ្យគេ គឺវាមិនមែនឯករាជ្យ និង អនាគតិ

---

[28] Geogia Wilkins ព្រឹត្តិប័ត្រសារព័ត៌មានភ្នំពេញប៉ុស "ការស៊ើបអង្កេតលើអំពើពុករលួយនៅសាលាក្តីខ្មែរក្រហមមិនដាក់នៅក្នុងរបៀបវារៈនៃការចរចារទេ" ចុះថ្ងៃទី ៦ មេសា ២០០៨ ទំព័រ ២ ។

[29] Geogia Wilkins និង វង់ សុខឃាង ព្រឹត្តិប័ត្រសារព័ត៌មានភ្នំពេញប៉ុស "ពុំមានការព្រមព្រៀងទេ ខណៈអង្គការសហប្រជាជាតិ និង រដ្ឋាភិបាលពុះពារដោះស្រាយអំពើពុករលួយនៅសាលាក្តីខ្មែរក្រហម ចុះថ្ងៃទី ៧ មេសា ២០០៨, Eang Mengleng & Isabelle Roughol ព្រឹត្តិប័ត្រសារព័ត៌មានដឹខេមបូដាលី "ការបន្តការចរចារអំពីការទប់ស្កាត់អំពើពុករលួយនៅ អ.វ.ត.ក ចុះថ្ងៃទី ៨ មេសា ២០០៨ ទំព័រ ២៩ ។

[30] Eang Mengleng & Bethany Linda ព្រឹត្តិប័ត្រសារព័ត៌មានដឹខេមបូដាលី "ការចរចាររបស់អង្គការសហប្រជាជាតិបានបញ្ចប់ដោយគ្មានកិច្ចព្រមព្រៀម ចុះថ្ងៃទី ៩ មេសា ២០០៨ ទំព័រ ២៧ ។ សូមមើលផងដែរ អត្ថបទរបស់លោក វង់ សុខឃាង នៃព្រឹត្តិប័ត្រសារព័ត៌មានភ្នំពេញប៉ុស "ពុំមានកិច្ចព្រមព្រៀងនៅកិច្ចចរចារពីអំពើពុករលួយនៅ អ.វ.ត.ក នោះឡើយ" ចុះថ្ងៃទី ៩ មេសា ២០០៨ ទំព័រ ៣ ។

[31] សេចក្តីថ្លែងការណ៍របស់លោក Peter Taksoe-Jensen ភ្នំពេញថ្ងៃទី ៨ មេសា ២០០៨ ។

ពិតប្រាកដនោះទេ”[32]។ លើសពីនេះទៅទៀត អង្គការទាំងពីរនេះ បានធ្វើការរិះគន់យ៉ាងខ្លាំងទៅលើការបរាជ័យនាពេលថ្មីៗនេះក្នុងការដោះស្រាយបញ្ហានេះ។ ពួកគេថ្លែងថា បញ្ហានេះបានបញ្ជូនសញ្ញាទៅប្រជាជនកម្ពុជាថា អំពើពុករលួយត្រូវបានគេអត់ឱន ហើយក៏មិនមានការទទួលខុសត្រូវដែរ ប្រសិនបើតម្រូវនោះ”[33]។ ពួកគេសន្និដ្ឋានថា នៅពេលពិនិត្យលើបញ្ហានេះដោយភ្ជាប់ជាមួយ “ការជ្រៀតជ្រែកចូលខាងនយោបាយយ៉ាងទូលំទូលាយដែលត្រូវបានរាយការណ៍” នោះបញ្ហាអំពើពុករលួយ “បានធ្វើឲ្យអន្តរាយដល់សុច្ចរិតភាព និង កិត្តិនាមរបស់ [អ.វ.ត.ក]”[34]។

ដ. នៅពេលដាក់បណ្តឹងឧទ្ធរណ៍នេះ មានការគំរាមកំហែងថា កាតព្វកិច្ចបើកប្រាក់បៀវត្សខែមេសាសម្រាប់បុគ្គលិកកម្ពុជា នឹងមិនអាចបំពេញបានឡើយ[35]។ ឆ្លើយតបទៅនឹងវិបត្តិដែលកើតឡើងផ្ទួនៗគ្នានេះ រដ្ឋាភិបាលអូស្ត្រាលីបានអនុញ្ញាតឲ្យបញ្ចេញមូលនិធិរបស់ខ្លួន ដែលសន្យាផ្តល់ឲ្យភាគីកម្ពុជារបស់តុលាការ បើទោះបីពុំមានកិច្ចព្រមព្រៀងប្រឆាំងនឹងអំពើពុករលួយដែលដាក់ទណ្ឌកម្មដោយអង្គការសហប្រជាជាតិក៏ដោយ។ ប៉ុន្តែ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (ហៅថា “UNDP”) ដែលគ្រប់គ្រងថវិការបស់ម្ចាស់ជំនួយ ថ្លែងនាពេលថ្មីៗនេះថាខ្លួន “មិនឋិតនៅក្នុងជំហ៊រដើម្បីបញ្ចេញថវិកានៅពេលនេះបានទេ” ដោយរង់ចាំ “ដំណោះស្រាយលើការចោទប្រកាន់នៃអំពើពុករលួយ”[36]។ ប៉ុន្តែបើពិចារណាទៅលើភាពជាប់គាំង

---

[32] សេចក្តីថ្លែងការណ៍រួមដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និង គណៈកម្មាធិកាសិទ្ធិមនុស្សអាស៊ាន, “កម្ពុជា ការអត់ឱននៃអំពើពុករលួយនៅសាលាក្តីខ្មែរក្រហម គឺមិនអាចទទួលយកបានឡើយ” ចុះថ្ងៃទី ១៧ មេសា ២០០៩, AHRC-STM-090-2009.

[33] សេចក្តីថ្លែងការណ៍រួមដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និង គណៈកម្មាធិកាសិទ្ធិមនុស្សអាស៊ាន, “កម្ពុជា ការអត់ឱននៃអំពើពុករលួយនៅសាលាក្តីខ្មែរក្រហម គឺមិនអាចទទួលយកបានឡើយ” ចុះថ្ងៃទី ១៧ មេសា ២០០៩, AHRC-STM-090-2009.

[34] សេចក្តីថ្លែងការណ៍រួមដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និង គណៈកម្មាធិកាសិទ្ធិមនុស្សអាស៊ាន, “កម្ពុជា ការអត់ឱននៃអំពើពុករលួយនៅសាលាក្តីខ្មែរក្រហម គឺមិនអាចទទួលយកបានឡើយ” ចុះថ្ងៃទី ១៧ មេសា ២០០៩, AHRC-STM-090-2009.

[35] លោក សុខ ខេមរា វិទ្យុសម្លេងសហរដ្ឋអាមេរិកជាភាសាខ្មែរ “ការបរាជ័យរបស់សាលាក្តី ដាក់ការទទួលខុសត្រូវលើប្រទេសផ្តល់ជំនួយ: អង្គការសហប្រជាជាតិ, ចុះថ្ងៃទី ២៣ មេសា ២០០៩ ។

[36] ជុន សាកាដា វិទ្យុសម្លេងសហរដ្ឋអាមេរិកជាភាសាខ្មែរ “ការអំពាវនាវឲ្យបញ្ចេញថវិការបស់តុលាការ” ចុះថ្ងៃទី ២ មេសា ២០០៩

រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ការឈានទៅដល់ចំនុចរួមមួយ ប្រហែលជាមិនអាចសម្រេចបានទេ។

6. ជាសង្ខេបមក "ដុំពកនៃអំពើពុករលួយ"[37] បន្តហោះហើរលើតុលាការ ហើយក៏ពុំមានការចង្អុលបង្ហាញណាដែលថា រាជរដ្ឋាភិបាល និង អង្គការសហប្រជាជាតិ ឬ ប្រទេសផ្តល់ជំនួយ មានឆន្ទះ និង/ឬ អាចចាត់វិធានការចាំបាច់ ដើម្បីលាងសំអាតខ្យល់អាកាសនេះទេ ។

## IV. ច្បាប់នៅជាធរមាន

### ក. យុត្តាធិការ និង បទដ្ឋានពិនិត្យលើបណ្តឹងលើឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ

7. វិធាន ៧៣ ផ្តល់ឲ្យអង្គជំនុំជម្រះនេះ "នូវអំណាចផ្តាច់មុខទៅលើ [...] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេច និង កិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត ដូចមានចែងនៅក្នុងវិធាន ៧៤ ។ អនុលោមទៅតាមវិធាន ៧៤(៣)(ខ) ជនត្រូវចោទធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាណាមួយរបស់សហចៅក្រមស៊ើបអង្កេត ដូចជា "ការបដិសេធសំណើសុំធ្វើកិច្ចស៊ើបសួរណាមួយ ដែលអនុញ្ញាតដោយវិធានផ្ទៃក្នុង[38]។ អនុលោមទៅតាមការអនុវត្តលើបណ្តឹងឧទ្ធរណ៍របស់ប្រព័ន្ធច្បាប់ស៊ីវិលដែលត្រូវបានបង្កើតឡើងយ៉ាងរឹងមាំ អង្គជំនុំជម្រះនេះ ត្រូវពិនិត្យលើសំណើនេះជាថ្មី ដោយមិនចាំបាច់យោងទៅលើការរកឃើញផ្នែកអង្គច្បាប់ ឬ អង្គហេតុរបស់ ក.ស.ច.ស ឡើយ។ នៅក្នុងការធ្វើសេចក្តីសម្រេច អង្គបុរេជំនុំជម្រះមានឆន្ទានុសិទ្ធិដើម្បីតម្កល់ កែប្រែ ឬ ព្យួរសេចក្តីសម្រេច ដោយផ្អែកលើសំណុំរឿងដែលមានស្រាប់ និង ព័ត៌មានបន្ថែមទាំងឡាយដែលផ្តល់ដោយភាគីនៃបណ្តឹងឧទ្ធរណ៍[39]។

---

[37] Ian Andrews, *l'Osservatore Romano*, "កងសន្តិសុខជាតិស៊ើបបានលើកឡើងពីការប្រាក់សងគុណនៅវិមានវ៉ាទីកង់ កាលពីថ្ងៃទី ១៩ ខែ មិថុនា ១៩៧៤។

[38] សូមមើលផងដែរ វិធាន ៥៥ (១០) ("ដីកាបដិសេធត្រូវមានសំអាងហេតុ ត្រូវជូនដំណឹងដល់ភាគី ហើយ ត្រូវបើកផ្លូវប្តឹងឧទ្ធរណ៍)

[39] សូមមើល [បណ្តឹងឧទ្ធរណ៍លើកមុន] ។

## ខ. សំណើសុំបំពេញកិច្ចស៊ើបសួរ, ឯករាជ្យភាព និង អនាគតិ និង ការិយាល័យរដ្ឋបាល

8. មេធាវីការពារសូមដាក់បញ្ចូលសំណើដែលមាននៅក្នុងកថាខ័ណ្ឌដប់បី (១៣) រហូតដល់កថាខ័ណ្ឌដប់ប្រាំ (១៥) នៃសំណើលើកទី ១១ ស្នើសុំបំពេញកិច្ចស៊ើបអង្កេតនេះ ។

## គ. គោលការណ៍ប្រឆាំងនឹងអំពើពុករលួយ

9. មេធាវីការពារសូមដាក់បញ្ចូលសំណើដែលមាននៅក្នុងកថាខ័ណ្ឌដប់ប្រាំមួយ (១៦) នៃសំណើនេះ ។ បន្ថែមពីលើនេះ មេធាវីការពារសូមណែនាំអង្គបុរេជំនុំជម្រះទៅលើបទអត្ថាធិប្បាយរបស់ចៅក្រម Désirée Bernard នៃតុលាការយុត្តិធម៌របស់ប្រទេសការ៉ាប៊ីន ស្តីពីផលប៉ះពាល់នៃអំពើពុករលួយទៅលើដំណើរការនីតិវិធីតុលាការ និង តួនាទីរបស់តុលាការនៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយៈ

ក. បុគ្គលិកគាំទ្ររបស់តុលាការ ត្រូវប្រកាន់ភ្ជាប់នូវបទដ្ឋានអកប្បកិរិយាសីលធម៌ខ្ពស់ សាកសម្បនឹងការទទួលខុសត្រូវ អនុវត្តច្បាប់ និងបំរើយុត្តិធម៌។ ពួកគេត្រូវទំនាក់ទំនងជាមួយសាធារណជនដោយសុច្ចរិត និងទៀងត្រង់ ប៉ុន្តែ ពួកគេងាយនឹងស្រើបស្រាលដោយសំណើពីភាគីនៃរឿងក្តីនៅតុលាការជាប្រចាំថ្ងៃ ដើម្បីក្លែងសំណុំរឿងនិងដកចេញឯកសារពីសំណុំរឿង ឬ បង្ហាញអង្គហេតុមិនត្រឹមត្រូវ ដើម្បីព្យាយាមដាក់ឥតទ្ធិពលលើចៅក្រម ដែលខ្លួនធ្វើការជាមួយ"[40]។

ខ. ដើម្បីដំណើរការប្រព័ន្ធតុលាការឲ្យមានប្រសិទ្ធិភាព យើងមិនត្រឹមតែធ្វើឲ្យមានយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែ យើងត្រូវធ្វើឲ្យគេមើលឃើញថា យុត្តិធម៌ពិតជាមានមែន។ ការយល់ឃើញរបស់សាធារណជន គឺមានសារៈសំខាន់ណាស់ ហើយអ្នកដែលគ្រប់គ្រងប្រព័ន្ធតុលាការ ត្រូវតែ

[40] Désirée Bernard, OR CCH "អំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការប៉ះពាល់ដល់សមត្ថភាពរបស់តុលាការក្នុងការគ្រប់គ្រងយុត្តិធម៌, សន្និសិទរបស់ប្រព័ន្ធកុំម៉ង់ឡូលលើកទី១៤ ខែ សីហា ២០០៥, ទំព័រ ៥។

បានគេមើលឃើញថា បានប្រតិបត្តិការងារយ៉ាងហ្មត់ចត់ដើម្បីលុបបំបាត់អំពើទុករលួយគ្រប់រូបភាព[41]។

គ. បទដ្ឋានក្រមសីលធម៌តុលាការ "មិនត្រូវអនុវត្តជាមួយចៅក្រមតែប៉ុណ្ណោះទេ ប៉ុន្តែ ត្រូវអនុវត្តចំពោះបុគ្គលិកគាំទ្រ និង បុគ្គលិកដទៃទៀត ដែលត្រូវបានជ្រើសរើសបំរើការងារនៅក្នុងប្រព័ន្ធ [...]។ បុគ្គលបែបនេះ ត្រូវតែបានដឹងថា ពួកគេគឺជាផ្នែកមួយដ៏សំខាន់នៃប្រព័ន្ធតុលាការ ហើយការប្រព្រឹត្តគាំទ្រងរបស់ពួកគេ នឹងឆ្លុះបញ្ចាំងពីរូបភាពអវិជ្ជមាននៃរដ្ឋបាលតុលាការទាំងមូល"[42]។

ឃ. តាមការពិត ដៃគូសំខាន់គឺតុលាការ និងអ្នកដែលមានតួនាទីនៅក្នុងរដ្ឋបាលតុលាការ ។ ការទទួលខុសដ៏ចម្បងចំពោះក្នុងការលុបបំបាត់អំពើពុករលួយពីប្រព័ន្ធតុលាការ គឺជាបន្ទុករបស់តុលាការ និង មន្ត្រីរដ្ឋបាលតុលាការ"[43]។

## ឃ. អំណាចជាប់មកជាមួយ

10. អំណាចជាប់មកជាមួយ គឺជាអំណាចទាំងឡាយដែលមិនបានមកពីច្បាប់លក្ខន្តិកៈ ឬអំណាចដែលផ្តល់ដោយប្រភពដទៃទៀតនៃច្បាប់នោះទេ ប៉ុន្តែ អំណាចទាំងនេះកើតចេញពីគោលបំណងរបស់តុលាការតែម្តង[44]។ អំណាចបែបនេះកប់ជ្រៅ ដែលចាំបាច់ថាតុលាការគ្រប់ទីកន្លែងទាំងអស់ ត្រូវបំពេញមុខ

---

[41] Bernard ទំព័រ ៥។

[42] Bernard ទំព័រ ៦។

[43] Bernard ទំព័រ ៧ និង ៨។

[44] មូលមើលស្នាដៃរបស់ Chester Brown ក្រោមចំណងជើងថា "អំណាចជាប់មកជាមួយរបស់តុលាការអន្តរជាតិ" នៅក្នុង Yearbook of International Law របស់អង់គ្លេស ឆ្នាំ ២០០៥ (Oxford 2006) ទំព័រ ២០៥ ("គោលបំណងនៃការជាប់មកជាមួយ គឺដើម្បីពិពណ៌នាអ្វីមួយដែល "កើតឡើង" នៅក្នុងអ្វីមួយដែលជាចាត់ទុកថា បង្កើតបានជាធាតុផ្សំមួយ ជាពិសេស ធាតុផ្សំសំខាន់នៃរបស់អ្វីមួយ, ជាកម្មសិទ្ធិរបស់មជ្ឈន្តិកៈរបស់ធម្មជាតិដែលត្រូវគេនិយាយឡើង" "អំណាចជាប់មកជាមួយ" អាចជាអ្វីមួយដែលកើតចេញពីការិយាល័យ តួនាទី ឬ លក្ខន្តិកៈ។ អំណាចជាប់មកជាមួយរបស់តុលាការ អាចកើតចេញពីគោលបំណងរបស់តុលាការដែលត្រូវបានបង្កើតឡើងច្បាប់")។ សូមមើលផងដែរ ស្នាដៃរបស់លោក Brown ទំព័រ ២២៧-២២៨ ។

ងារតុលាការយ៉ាងត្រឹមត្រូវ និងប្រសិទ្ធិភាព[45]"។ ការទទួលស្គាល់អំណាចដែលជាប់មកជាមួយនេះ ដែលត្រូវបានបង្កើតឡើងយ៉ាងរឹងរាំនៅក្នុងប្រព័ន្ធច្បាប់កុម៉ងឡូរបស់អង់គ្លេស[46] ប៉ុន្តែ ត្រូវបានគេស្គាល់ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូផងដែរ[47] ត្រូវបានបញ្ចូលទៅក្នុងតុលាការជាតិ និងអន្តរជាតិទំនើប។ តុលាការទាំងអស់មានអំណាចនេះ រួមមានសមត្ថកិច្ចដើម្បីធានាថា ដំណើរការនីតិវិធីជាមូលដ្ឋាន របស់តុលាការ ត្រូវតែត្រឹមត្រូវ និង ទប់ស្កាត់ការរំលោភបំពានទៅលើដំណើរការនីតិវិធី និង/សិទ្ធិ[48]។

---

សូមកត់សំគាល់ថា អត្ថិភាពនៃអំណាចជាប់មកជាមួយត្រូវបានគាំទ្រសោយទ្រឹស្តី"។ Brown ទំព័រ ១៩៧ ("បានស្រង់ស្នាដៃ scholarship ជាច្រើន ចាប់តាំងពីឆ្នាំ ១៩៦០ រហូតដល់ ២០០៥)។

[45] ស្នាដៃរបស់លោក Brown ទំព័រ ២២៨ ដល់ ២២៩ ។

[46] Lord Blackburn: 'from early times [...] the court had inherently in its power the right to see that its process was not abused by a proceeding without reasonable grounds, so as to be vexatious and harassing—the court had a right to protect itself against such an abuse'. (Brown 205, n 58) Lord Morris: 'There can be no doubt that a court which is endowed with a particular jurisdiction has powers which are necessary to enable it to act effectively within such jurisdiction. I would regard them as powers which are inherent in its jurisdiction. A court must enjoy such powers in order to enforce its rules of practice and to suppress any abuses of its process and to defeat any attempted thwarting of its process.' (Brown 205, n 59) Lord Nicholls: 'My Lords, every court has an inherent power and duty to prevent abuse of its process. This is a fundamental principle of the rule of law. By recourse to this principle courts ensure that executive agents of the State do not misuse the coercive, law-enforcement functions of the courts and thereby oppress citizens of the State.' R v Looseley, Attorney-General's Reference (no 3 of 2000), ([2001] United Kingdom House of Lords Decisions 53), para 1. [JV: 'It's YOUR honor!'] *N.B.* Many other common-law jurisdictions have claimed inherent powers in various circumstances: 'to make rules of court and practice directions, to prevent abuse of the court's process, to remand cases involving pendent claims, to stay proceedings, to correct any injustice caused by an earlier order, such as where an individual is subjected to procedural unfairness, and to allow the admission of evidence'. (Brown 205–206, nn 60–65) *See, e.g., United States v. Holmes*, 343 A.2d 272, 277 (D.C. 1975); *see also United States v. Edelin*, 134 F. Supp. 2d 45, 48 (D.D.C. 2001) (trial court has inherent judicial power to provide procedures necessary for "just and efficient resolution" of judicial proceedings); *In Re Jam J.*, 825 A.2d at 917 (trial court has inherent authority to "control the conduct of the proceedings before it," "to ensure that . . . all parties are treated fairly, and [to see] that justice is done"); *Hicks-Bey*, 649 A.2d at 575 (same); *Oesby v. United States*, 398 A.2d 1, 10 (D.C. 1977) ("recogniz[ing] that a trial judge is accorded broad discretion in supervising trial proceedings").

[47] សូមមើល Brown, ទំព័រ 206 ("ស្របពេលប្រើប្រាស់អំណាចដែលភ្ជាប់មកជាមួយ ដែលមានលក្ខណៈទូទៅជាងនៅបណ្តាប្រទេសដែលប្រើប្រាស់ប្រព័ន្ធច្បាប់កុម៉ង់ឡូ ហើយការអនុវត្តអំណាចយុត្តាធិការដោយតុលការដែលមិនត្រូវបានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ ឬ វិធាន គឺមិនសូវកើតមាននៅក្នុងប្រទេសដែលអនុវត្តច្បាប់ស៊ីវិលេទ ដូចជាប្រទេសបារាំង អាឡឺម៉ង់ ណូវែស៊ុយអ៊ែត ជាដើម ។

[48] ទ្រឹស្តីរបស់ប្រព័ន្ធច្បាប់កុម៉ង់ឡូនៃ "ការរំលោភបំពានលើដំណើរការ" គឺជាប់ពាក់ព័ន្ធជាមួយទស្សនភាពនៃ "ការរំលោភសិទ្ធិ" ដែលមានអត្ថន័យស្រដៀងគ្នានឹងប្រព័ន្ធច្បាប់ស៊ីវិល Brown, ទំព័រ 231 ។ ទ្រឹស្តីនេះត្រូវបានទទួលស្គាល់ដោយករណីតិចបំផុត ៩ ដែររបស់តុលាការយុត្តិធម៌អន្តរជាតិ, Brown, p 232។ ឧទាហរណ៍ដ៏ល្អនៃអំណាចភ្ជាប់មកជាមួយរបស់តុលាការ រួមមាន:

11. យុត្តិកម្មសម្រាប់ការអនុវត្តន៍អំណាចដែលមានជាប់មកជាមួយ មានពីរផ្នែក គឺផ្នែកឯកជន និងផ្នែកសាធារណៈ។ ផ្នែកដំបូង គឺជាប់ទាក់ទងទៅនឹងការដោះស្រាយជម្លោះឯកជន នៅចំពោះមុខសាលាជម្រះក្តី ឯផ្នែកបន្ទាប់ គឺស្វែងរកការធានាឲ្យមានការចាត់ចែងយុត្តិធម៌ឲ្យបានត្រឹមត្រូវ ដែលជាបញ្ហាបទដ្ឋានទូទៅមួយ។[49] ការសម្តែងឲ្យឃើញយ៉ាងជាក់លាក់ពីមុខងារសាធារណៈរបស់សាលាជម្រះក្តីអន្តរជាតិ [ដែលជាប់ទាក់ទងពិសេសទៅនឹងបរិបទ អ.វ.ត.ក/កម្ពុជា] គឺតួនាទីដែលតុលាការអន្តរជាតិដើរតួនៅក្នុងការបញ្ជាក់បង្ហាញ និង ការអភិវឌ្ឍន៍ជាហូរហែរនៃច្បាប់អន្តរជាតិ ព្រមទាំងការលើកកម្ពស់ "ផលប្រយោជន៍សហគមន៍ឲ្យបានកាន់តែទូលំទូលាយ"[50]។

12. ទស្សនៈទាននៃអំណាចដែលមានជាប់មកជាមួយ គឺដំបូងត្រូវបានទទួលស្គាល់ជាអន្តរជាតិដោយតុលាការយុត្តិធម៌អន្តរជាតិ (ហៅកាត់ "ICJ") នៅក្នុងឆ្នាំ ១៩៧៤ ÷

> "[...] ម្យ៉ាង តុលាការមានយុត្តាធិការជាប់មកជាមួយ ដែលបង្កលក្ខណៈងាយស្រួលឲ្យខ្លួនចាត់វិធានការដែលអាចតម្រូវឲ្យមាន ដើម្បីធានាថា ការអនុវត្តយុត្តាធិការរបស់ខ្លួនទៅលើអង្គហេតុ[...] មិនត្រូវបានធ្វើឲ្យរួញរានោះឡើយ និង ម្យ៉ាងវិញទៀត គឺដើម្បីផ្តល់នូវការដោះស្រាយបញ្ហាទាំងអស់នៅក្នុងវិវាទ ឲ្យបានត្រឹមត្រូវតាមលំដាប់លំដោយ [...]។ ផ្អែកលើមូលដ្ឋានដែលតុលាការត្រូវបានផ្តល់អំណាចពេញលេញ ដើម្បីធ្វើការស្វែងរកអ្វីក៏ដោយដែលអាចចាំបាច់សម្រាប់គោលបំណងដែលទើបតែបានលើកឡើងនេះ នោះយុត្តាធិការដែលមានមកជាមួយបែបនេះ កើតចេញពីអត្ថិភាពរបស់តុលាការដែលជាស្ថាប័នតុលាការមួយបង្កើតឡើងតាមការព្រមព្រៀងរបស់រដ្ឋនានា និងត្រូវបានផ្តល់ជូនតុលាការនេះ

---

ការសម្រេចលើអំណាចរបស់ខ្លួន, ការអនុញ្ញាតនូវវិធានកាតបណ្តោះអាសន្ន, ការអនុញ្ញាតនូវអន្តរគមន៍របស់តតីយជន ការបកស្រាយ, ការពិនិត្យឡើងវិញ, ការពិចារណាឡើងវិញ, និង/ឬ ការកែប្រែសាលក្រម, សេចក្តីសម្រេចនិង/ឬ លិខិតកត់យុត្តិ ការបង្កើតវិធាននីតិវិធី/ការប្រព្រឹត្តទៅ និង ការចេញដីកាបង្គាប់, ការចេញសេចក្តីណែនាំអនុវត្ត, ការសម្រេចលើបណ្តឹងតប, ការងហាមឃាត់ការសេចម្រេចលើបញ្ហាជាក់លាក់ ប្រសិនបើមិនចាំបាច់ក្នុងការដោះស្រាយបញ្ហា, ការបង្កើតនីតិវិធីពិសេសជាមធ្យោបាយរក្សាអំណាចលើវិវាទ, ពិនិត្យនៅកន្លែងប្រព្រឹត្តបទល្មើស, ការបង្គាប់នូវការរៀបចំរបាយការណ៍ជំនាញ និងការផ្តល់ឧបាស្រ័យដល់ភាគីរងគ្រោះ/ការផ្តល់ចំណងជំងឺចិត្ត ។ Brown, p 200 (n 24), 201 (nn 25–28), 201–202 (nn 33–35), 212–215, 216 (nn 129–135), 217–222.

[49] Brown ទំព័រ ១៩៨, ២០៨ ដល់ ២០៩ កំណត់សំគាល់លេខ ៨២, ២៣០, ២៣១ និង ២៣៧ ។

[50] Brown ទំព័រ ២៣២ ដល់ ២៣៣ និង ២៣៥ ។

> ក្នុងគោលបំណងថា មុខងារតុលាការជាមូលដ្ឋានរបស់ខ្លួនអាចត្រូវបានធានា។ [...] វាពិតជាអំណាចដែលមានមកជាមួយមែន ទោះបីជាយុត្តាធិការថែដន្យភាគច្រើននេះ (មិនទាំងអស់ក៏ដោយ) ត្រូវបានផ្តល់ជូនយ៉ាងជាក់លាក់នៅក្នុងលក្ខន្តិកៈរបស់តុលាការ ឬនៅក្នុងវិធានរបស់តុលាការ ដែលលក្ខន្តិកៈនេះផ្តល់អំណាចឱ្យតុលាការដាក់ចេញនូវអំណាចដើម្បីអនុវត្ត ដែលជាស្ថានភាពចាំបាច់មួយរបស់តុលាការនេះ ឬតុលាការផ្សេងទៀត ដែលមិនអាចមានដំណើរការដំណើរការអ្វីបាននោះ"។[51]

ចាប់តាំងពីពេលនោះមក វិធីសាស្ត្ររបស់ ICJ ដែលសង្កេតមើលបញ្ហានេះ "តាមទស្សនៈយល់ឃើញពីការចាត់ចែងយុត្តិធម៌អោយបានត្រឹមត្រូវ"[52] ត្រូវបានអនុម័តឡើងដោយតុលាការអន្តរជាតិ ភាគច្រើន បើមិនទាំងអស់នោះទេ ដែលក្នុងនោះរួមមាន ECHR[53], ICTY[54] និង ICTR[55]

---

[51] Brown ២១១-២១២ [ដកស្រង់ការសាកល្បងអាវុធនុយក្លេអ៊ែ N (ប្រទេសអូស្ត្រាលី តទល់នឹង ប្រទេសបារាំង), [១៩៧៤] របាយការណ៍ ICJ ២៥៣, ២៥៩-២៦០ និង ការអះអាងពីការសាកល្បងអាវុធនុយក្លេអ៊ែ (ប្រទេសនូវែលហ្សេឡង់ តទល់នឹង ប្រទេសបារាំង [១៩៧៤], របាយការណ៍របស់ ICJ ១៩៧៤, ៤៦៣ ទំព័រ ២៥៩-២៦០ កថាខណ្ឌ ២៣។ ប្រទេសកាមេរូនភាគខាងជើង (ប្រទេសកាមេរូន តទល់នឹង ចក្រភពអង់គ្លេស) [១៩៦៣] របាយការណ៍របស់ ICJ ១៥, ៩៧, ១០៣)។

[52] Brown ទំព័រ ១៩៥ ។

[53] សូមមើលឧទាហរណ៍នៃរឿងក្តីរវាង *Putz* តទល់នឹង ប្រទេសអូទ្រីស [...] កថាខណ្ឌ ៣៣, *Hutten-Czapska* តទល់នឹង ប្រទេសប៉ូឡូញ, សាលដីកា (ការដោះស្រាយប្រកបដោយមិត្តភាព), យោបល់ស្របគ្នារបស់ចៅក្រម Ziemele, បណ្តឹងឧទ្ធរណ៍លេខ ៣៥០១៤/៩៧, ECHR ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៨ ទំព័រ ២៨។

[54] សូមម៉លឧទាហរណ៍នៃរឿងក្តីរវាងរដ្ឋអាជ្ញា តទល់នឹង *Mucić*, និងអ្នកផ្សេងទៀត, IT-96-21-A ស្ទួន "សាលដីកា និងការផ្តន្ទាទោស" ចុះថ្ងៃទី៨ មេសា ២០០៣ កថាខណ្ឌទី ១៦, រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង Tadić, IT-94-1-A-R77 "សាលដីកាស្តីពីការមាក់ងាយ ប្រឆាំងមកលើមេធាវីមុនឈ្មោះ Milan Vujin ចុះថ្ងៃទី ៣១ មករា ២០០០ កថាខណ្ឌទី ១៣, រឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង Blaškić, IT-95-14-AR108 ស្ទួន "សាលដីកាស្តីពីសំណើរបស់សាធារណៈរដ្ឋក្រូអាស៊ី ស្នើសុំឱ្យពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទី II ចុះថ្ងៃទី១៨ កក្កដា ១៩៩៧ និង ថ្ងៃទី២៩ តុលា ១៩៩៧ កថាខណ្ឌ ២៥ កំណត់សម្គាល់លេខ ២៧ ។ ខណ្ឌ

[55] សូមមើលជាឧទាហរណ៍ *រដ្ឋអាជ្ញា តទល់នឹង* *Nyiramasuhuko* និង *Ntahobali*, ICTR-97-21-T, "សេចក្តីសម្រេចស្តីពីសារណារបស់ *Ntahobali* ដើម្បីដកហូតមេធាវីការពារ" ចុះថ្ងៃទី២២ មិថុនា ២០០១ កថាខណ្ឌ ២០។ *រដ្ឋអាជ្ញា តទល់នឹង* *Barayagwiza*, ICTR-97-19-T, "សេចក្តីសម្រេចស្តីពីសារណារបស់មេធាវីការពារស្នើសុំការដកហូត" ចុះថ្ងៃទី២ វិច្ឆិកា ២០០០។ ("យោបល់ស្រប និងយោបល់ដាច់ដោយឡែករបស់ចៅក្រម Gunawardana")។ *Kanyabashi* *តទល់នឹង* *រដ្ឋអាជ្ញា*, ICTR-96-15-A, "សេចក្តីសម្រេចស្តីពីពាក្យបណ្តឹងរបស់មេធាវីការពារចំពោះបណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំស្តីពីយុត្តាធិការរបស់សាលាដំបូងទី I" ("យោបល់ខ្វែងគំនិតគ្នារបស់ចៅក្រម Shahabuddeen, ទំព័រ ១៧")។

ដែលតុលាការនីមួយៗទទួលស្គាល់អំណាចដែលមានមកជាមួយរបស់ខ្លួន ដើម្បីត្រួតពិនិត្យពីដំណើរការនីតិវិធីរបស់ខ្លួនផ្ទាល់ តាមមធ្យោបាយមួយដើម្បីធានាថា យុត្តិធម៌ត្រូវបានបង្កើតឡើង។ អាស្រ័យហេតុនេះ "តុលាការ និងសាលាជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិដទៃទៀត [...] ទទួលបានការកាន់កាប់តាមនិយមន័យនៃអំណាចមានជាប់មកជាមួយដើម្បីដោះស្រាយទង្វើ ដែលជ្រែតជ្រែកមកលើការចាត់ចែងយុត្តិធម៌របស់ខ្លួន [...][56]។

## ខ. ភស្តុតាងដែលប្រទាក់ប្រទាក់ប្រឡូក

13 ទាក់ទងទៅនឹងភាពមិនប្រក្រតីទាំងឡាយដែលអាចកើតមាន មុនពេលដាក់ជូនរឿងក្តីនេះ តុលាការត្រូវតែ"ប្រាកដខ្លួនឯងថា ដំណើរការនីតិវិធីទាំងមូលគឺមានភាពយុត្តិធម៌"[57] រួមទាំង "មធ្យោបាយពាក់ព័ន្ធជាមួយភស្តុតាង"[58] ដោយសារតែតុលាការមានឆន្ទានុសិទ្ធិផ្តាច់មុខដើម្បីទទួលយក ឬច្រានចោលភស្តុតាង[59] នោះការសម្រេចចិត្តបែបនេះត្រូវតែធ្វើឡើងដោយប្រុងប្រយ័ត្នបំផុតទាក់ទង ទៅនឹងកាលៈទេសៈដែល "មានប្រយោជន៍បំផុតដល់ការសម្រេចចិត្តប្រកបដោយភាពត្រឹមត្រូវនៅចំពោះមុខអង្គជំនុំជម្រះនេះ"[60]។ សូម្បីតែនៅក្រោយពេលដែលភស្តុតាងនេះត្រូវបានទទួលយករួចហើយក៏ក្តី ក៏វាអាចចាំបាច់ដើម្បីច្រានចោលភស្តុតាង ដែលតម្លៃសាកល្បងរបស់វាមានទម្ងន់យ៉ាងធំធេងដោយតម្រូវការធានាឲ្យមានការជំនុំ

---

[56] Silvia D'Ascoli, 'ការផ្តន្ទាទោសពីបទងាក់ងាយតុលាការ នៅតុលាការយុត្តិធម៌អន្តរជាតិ: បញ្ហាដែលមិនអាចប្រមើលមើលជាមុនបាន ទាក់ទងទៅនឹងការផ្តន្ទាទោស និងទណ្ឌកម្ម', នៅក្នុងព្រឹត្តិប័ត្រយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ (Oxford 2007)ទំព័រ ៧៣៨។

[57] Miailhe តទល់នឹង ប្រទេសបារាំង (លេខ ២), ចុះថ្ងៃទី ២៦ កញ្ញា ១៩៩៦ កថាខណ្ឌ ៤៣ ។

[58] Helle តទល់នឹង ប្រទេសហ្វាំងឡង់, បណ្តឹងលេខ ១៥៧/១៩៩៦/៧៧៦/៩៧៧ ចុះថ្ងៃទី ១៩ ធ្នូ ១៩៩៧ កថាខណ្ឌ ៥៣ ។

[59] អ្នកនិពន្ធ, តុលាការព្រហ្មទណ្ឌអន្តរជាតិ Archbold: ការអនុវត្តន៍, នីតិវិធី និង ភស្តុតាង, (2005, Sweet &Maxwell) § 9-27 ។

[60] រដ្ឋអាជ្ញា តទល់នឹង Milosević, IT-02-54-AR73.2, សេចក្តីសម្រេចស្តីពីការទទួលយកភស្តុតាងរបស់អ្នកស៊ើបអង្កេតនៃស្ថាប័នអយ្យការ (Decision on Admissibility of Prosecution Investigator's Evidence), ចុះថ្ងៃទី ៣០ កញ្ញា ២០០២ កថាខណ្ឌ ១៨ ។

ជម្រះក្តីមួយប្រកបដោយភាពត្រឹមត្រូវ[61] ឬអាចនិយាយម្យ៉ាងទៀតបានថា "ការធ្វើឱ្យខូចប្រយោជន៍របស់ភស្តុតាងនោះ នឹងបណ្តាលឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ភាពត្រឹមត្រូវ" នៃដំណើរការនីតិវិធី។[62]

14 ក្នុងន័យនេះ វិធាន ៩៥ របស់ ICTY និង ICTR ចែងពី "ការច្រានចោលភស្តុតាងដោយសារមូលហេតុដែលភស្តុតាងត្រូវបានទទួល"។ ភស្តុតាងដែល "អាចធ្វើឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរដល់សុច្ចរិតភាពនៃដំណើរការនីតិវិធី" នឹងត្រូវបានច្រានចោល។ ដូចគ្នានេះដែរ វិធាន ៩៥ របស់ SCSL ចែងថា "មិនមានភស្តុតាងណាត្រូវបានទទួលនោះទេ ប្រសិនបើការទទួលយកភស្តុតាងនោះ អាចនាំឱ្យការចាត់ចែងយុត្តិធម៌ធ្លាក់ទៅក្នុងកេរ្តិ៍ឈ្មោះអាក្រក់"។ ICTY បានសម្រេចថា ប្រភពនៃ ភស្តុតាងគឺជាមូលដ្ឋានចំពោះភាពគួរឱ្យទុកចិត្តបានរបស់ខ្លួន ហើយត្រូវតែ "បានទទួលនៅក្រោមកាលៈទេសៈដែលមិនបណ្តាលឱ្យមានការមន្ទិលសង្ស័យទៅលើគោលបំណង និងចរិតលក្ខណៈរបស់វា"[63]។

15 យុត្តិសាស្ត្រពាក់ព័ន្ធបានបង្ហាញថា មានកាលៈទេសៈមួយចំនួន ដែលត្រូវតែច្រានចោលភស្តុតាង ដើម្បីទទួលបានសុច្ចរិតភាពនៃដំណើរការនីតិវិធី:

ក. តុលាការកំពូលសហរដ្ឋអាមេរិកបានអនុម័តនូវទ្រឹស្តីនៃ "ភស្តុតាងទុច្ចរិត"[64] ដែលតម្រូវឱ្យទប់ស្កាត់ភស្តុតាងដែល "តាមការយល់ដឹងខ្លះថា ជាផលិតផលនៃសកម្មភាពមិនស្របច្បាប់របស់រដ្ឋាភិបាល"[65]។ យុត្តិសាស្ត្រនេះច្រានចោលភស្តុតាងក្លាយដែលបានទទួលដោយ "ការប្រើប្រាស់អនីត្យានុកូលភាព [បែបនេះ]។[66]

ខ. ECHR បានរកឃើញថា វាមានសារៈប្រយោជន៍ក្នុងការសំអាងទៅលើយុត្តិសាស្ត្រតុលាការសហរដ្ឋអាមេរិក ក្នុងករណីដែល "ភាពត្រឹមត្រូវនៃដំណើរការនីតិវិធីព្រហ្មទណ្ឌស្ថិតនៅក្រោម

---

[61] រដ្ឋអាជ្ញា តទល់នឹង Akayesu, ICTR-96-4-T, សាលក្រម ចុះថ្ងៃទី ២ កញ្ញា ១៩៩៨ កថាខណ្ឌ ១៣៦ ។

[62] រដ្ឋអាជ្ញា តទល់នឹង Bagosora និងអ្នកផ្សេងទៀត, ICTR-98-41-AR93, 'សេចក្តីស្តីពីបណ្តឹងឧទ្ធរណ៍ បន្ទាន់បន្ទុំរបស់រដ្ឋអាជ្ញាទាក់ទងនឹងការច្រានចោលភស្តុតាង', ចុះថ្ងៃទី ១៩ ធ្នូ ២០០៣ កថាខណ្ឌ ១៦។

[63] រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត, IT-96-21-T, 'សេចក្តីស្តីពីបណ្តឹងរបស់ Mucić ចំពោះការច្រានចោលភស្តុតាង', ចុះថ្ងៃទី ២ កញ្ញា ១៩៩៧ កថាខណ្ឌ ៤១។

[64] Nardone តទល់នឹង សហរដ្ឋអាមេរិក, 308 U.S. 338, 341 (1939)

[65] Nix តទល់នឹង Williams 467 U.S. 431, 444 (1984)

[66] Wong Sun តទល់នឹង សហរដ្ឋអាមេរិក, 371 U.S. 471, 485-88 (1963);

ការត្រួតពិនិត្យ ត្រូវបានគេធ្វើឱ្យមានភាពលំអៀងដែលមិនអាចទាមទារមកវិញបាន[67] និងបានលើកឡើងថា ការទទួលយកសេចក្តីថ្លែងដែលទទួលយកបានដោយការរំលោភទ្រឹស្តី "[ដំណើរនីតិវិធី] ប្រឡាក់ប្រឡូកទាំងស្រុង"[68]។

គ. នៅក្នុងចក្រភពអង់គ្លេស សាលាឧទ្ធរណ៍បានច្រានចោលការផ្តន្ទាទោសលើជនជាប់ចោទជាភេរវករកងទ័ពសាធារណៈរដ្ឋអៀរឡង់ (IRA) នៅក្នុងរឿងក្តីគួរឱ្យកត់សម្គាល់ពីរដែលត្រូវបានពិចារណាថា នគរបាលកែខៃចម្លើយសារភាព និងបានបំភាន់តុលាការជាបន្តបន្ទាប់។ នៅក្នុងរឿងក្តី 'Guilford 4' សាលាឧទ្ធរណ៍បានរកឃើញថា: "ប្រសិនបើ [នគរបាល] ត្រូវបានគេរៀបចំឱ្យនិយាយកុហកបែបនេះ នោះភស្តុតាងរបស់ពួកគេទាំងមូលក្លាយទៅជាការមន្ទិលសង្ស័យ"[69]។ ស្រដៀងគ្នានេះផងដែរ រឿងក្តី 'Birmingham 6'[70] ត្រូវបានសម្រេចថា "ភស្តុតាងរបស់នគរបាលនៅក្នុងសវនាការ គឺមិនអាចឱ្យជឿទុកចិត្តបានទាល់តែសោះ [...] ដោយហេតុថា ការផ្តន្ទាទោសនោះគឺមិនមានសុវត្ថិភាព និងមិនអាចទទួលយកបាន"[71].

16 រឿងក្តីទាំងនេះបង្ហាញពីតម្រូវការឱ្យធ្វើសកម្មភាពឱ្យបានឆាប់រហ័យ នៅសញ្ញាណដំបូងនៃបញ្ហាជាសក្តានុពលទាំងឡាយ ដែលទាក់ទងទៅនឹងការប្រមូលភស្តុតាង។ ពាក្យស្លោកមួយនិយាយថា ការការពារប្រសើរជាងការព្យាបាល[72]។

---

[67] Panovits សហរដ្ឋអាមេរិក, Cyprus, ចុះថ្ងៃទី ១១ ធ្នូ ២០០៨, ពាក្យបណ្តឹងលេខ ៤២៦៨/០៤ យោបល់រួមស្របគ្នា របស់ចៅក្រម Spielmann និងចៅក្រម Jebens កថាខណ្ឌ ១០ និង ១១។

[68] ដូចគ្នា, សូមមើលផងដែរ Gäfgen តទល់នឹង ប្រទេសអាល្លឺម៉ង់, ចុះថ្ងៃទី ៣០ មិថុនា ២០០៨, ពាក្យបណ្តឹងលេខ ២៩៧៨/០៥, កថាខណ្ឌ ១០៥ ។

[69] R តទល់នឹង Richardson; R តទល់នឹង Conlon; R តទល់នឹង Armstrong; R តទល់នឹង Hill, The Times, ចុះថ្ងៃទី ២០ តុលា ១៩៨៩។

[70] R តទល់នឹង McIlkenny និងអ្នកដទៃទៀត, [១៩៩២] All ER 417, 93 របាយការណ៍អង្គជំនុំជម្រះសាលាឧទ្ធរណ៍លេខ ២៨៧។

[71] ដូចគ្នា ។

[72] សូមមើល Benjamin Franklin, Poor Richard's Almanac ('An ounce of prevention is worth a pound of cure.'). ចំណាំ: តុលាការនៅទូទាំងពិភពលោកបានទទួលស្គាល់ពីការអនុវត្តវិធីសាស្ត្រប្រកបដោយសុភនិច្ឆ័យរួមចំពោះបញ្ហាផ្លូវច្បាប់ ដែលស្មុគស្មាញ។

## ច. ការប្រើប្រាស់អស់ដំណោះស្រាយ

17. យោងតាមគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ "ត្រូវប្រើប្រាស់ឲ្យអស់ច្បាប់ក្នុងស្រុកឲ្យអស់សិន មុននឹងចាប់ផ្តើមប្រើប្រាស់ច្បាប់អន្តរជាតិ"[73]។ វិធាននេះ មានប្រសិទ្ធភាពរាំងមិនឲ្យបណ្តឹងមួយឈានទៅដល់កម្រិតអន្តរជាតិ លើកលែងតែ និងរហូតទាល់តែដើមបណ្តឹងបានប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ ដែលអាចមានដល់ខ្លួន នៅក្នុងរដ្ឋដែលត្រូវបានចោទប្រកាន់ឲ្យទទួលខុសត្រូវចំពោះការរំលោភនោះ[74]។ ក្នុងខណៈដែលទស្សនៈនេះមិនអាចអនុវត្តដោយផ្ទាល់នៅក្នុងរង្វង់វិស័យច្បាប់អន្តរជាតិបាន នោះសនិទានភាពនៅពីខាងក្រោយវិធានទូទៅ និងដោយការពន្លាតអញ្ញត្រកម្មរបស់វិធាននេះ គឺមានសារៈប្រយោជន៍បំផុតនៅក្នុងករណីនេះ។ សនិទានភាពបែបនោះរួមមាន (i) ការគោរព "អធិបតេយ្យភាព និងយុត្តាធិការរបស់រដ្ឋដែលមានសមត្ថកិច្ចដោះស្រាយបញ្ហានោះតាមរយៈស្ថាប័នតុលាការរបស់ខ្លួន"[75] និង (ii) ភាពចាំបាច់ក្នុងការធានាថា "រដ្ឋនោះមិនមានឆន្ទៈឲ្យខុសទៅជាត្រូវនោះទេ"[76]។ ទោះជាយ៉ាងណាក៏ដោយ លុះណាតែដំណោះស្រាយតាមផ្លូវច្បាប់ "ប្រកបដោយប្រសិទ្ធភាព" ដែលអាចមាន "ដែលជាបញ្ហានៃលទ្ធភាពសមហេតុសមផល" និង "លទ្ធភាពនៃការផ្តល់ការកែតម្រូវ" ត្រូវបានប្រើឲ្យអស់លទ្ធភាពសិន[77]។ ប្រសិនបើដំណោះស្រាយតាមច្បាប់ក្នុងស្រុកមិនបំពេញលក្ខណៈវិនិច្ឆ័យទាំងនេះបានទេ នោះមិនចាំបាច់ប្រើប្រាស់វាឲ្យអស់លទ្ធភាព មុននឹងស្វែងរកដំណោះស្រាយខាងក្រៅនោះទេ។

18 ដំណោះស្រាយតាមផ្លូវច្បាប់ត្រូវបានរកឃើញថាមិនមានប្រសិទ្ធភាព ហើយជាផលវិបាល មិនតម្រូវឲ្យប្រើប្រាស់អស់លទ្ធភាពនោះទេ ឧទាហរណ៍ ក្នុងករណីដែលតុលាការជារណបរបស់រដ្ឋាភិបាល ឬមានការពន្យារមិនសមហេតុផល នៅក្នុងការចាត់ចែងដំណោះស្រាយតាមផ្លូវច្បាប់។[78] លើសពីនេះទៅទៀត កាលៈទេសៈនៃអង្គហេតុអាចនាំឲ្យកើតមានដំណោះស្រាយតាមផ្លូវច្បាប់មួយ ដែលមិនមាន

---

[73] រឿងក្តី Interhandle (ប្រទេសស្វីស តទល់ជាមួយ សហរដ្ឋអាមេរិក) [១៩៥៩]) របាយការណ៍របស់ ICJ លេខ ២៧ ។

[74] សូមមើលជាឧទាហរណ៍ Ian Brownlie, គោលការណ៍នៃច្បាប់សាធារណៈអន្តរជាតិ, 6th ed (Oxford, 2003), ទំព័រ ៤៧២។

[75] M. Sørensen, សៀវភៅច្បាប់សាធារណៈអន្តរជាតិ, (St. Martin's 1968), ទំព័រ ៥៨៤។

[76] E.M. Borchard, ការការពារប្រជាពលរដ្ឋនៅបរទេសតាមផ្លូវការទូត (Kraus 1970), ទំព័រ ៨១៧។

[77] Brownlie, ទំព័រ ៤៧៤; Amerasinghe, ទំព័រ ១៨២; Oppenheim, ទំព័រ ៥២៥; Sørensen, ទំព័រ ៥៨៨។

[78] សូមមើលជាឧទាហរណ៍ *Robert E. Brown case* (1923), 6 R.I.A.A. p120 at p129.

ប្រសិទ្ធភាព[79] ដូចជា "មានភស្តុតាងបញ្ជាក់ពីអត្ថិភាពនៃការអនុវត្តន៍ ឬគោលនយោបាយ ដែលបានបញ្ជា ឬបណ្តែតបណ្តោយដោយរដ្ឋាភិបាល ដែលជាបច្ច័យរារាំងមិនឱ្យបុគ្គលមួយចំនួនពីស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់ក្នុងស្រុក"[80]។ តាមការពិតទៅ តុលាការត្រូវតែ "ប្រាកដនិយម មិនមែនត្រឹមតែអត្ថិភាពនៃដំណោះស្រាយតាមផ្លូវច្បាប់ជាផ្លូវការ នៅក្នុងប្រព័ន្ធច្បាប់ប៉ុណ្ណោះទេ [...] ប៉ុន្តែថែមទាំងប្រាកដនិយមពីបរិបទទូទៅ ដែលខ្លួនធ្វើប្រតិបត្តិការផងដែរ" និងនៅគ្រប់កាលៈទេសៈទាំងអស់នៃរឿងក្តី ត្រូវតែ "ពិនិត្យមើល ថាតើអ្នកអនុវត្តបានធ្វើអ្វីៗទាំងអស់ដែលខ្លួនរំពឹងទុកប្រកបដោយហេតុផល ចំពោះដំណោះស្រាយតាមច្បាប់ជាតិអស់ពីលទ្ធភាពដែរឬយ៉ាងណា។[81] ការខិតខំស្វែងរកដំណោះស្រាយតាមផ្លូវតុលាការអាច "មិនមានខ្លឹមសារ" នៅពេលដែល"ស្ថានភាពទូទៅ" [...] ត្រូវបានគេយល់ថា ដើម្បីបង្កើតឧបសគ្គចំពោះដំណើរការ ជាប្រក្រតីនៃប្រព័ន្ធចាត់ចែងយុត្តិធម៌"[82]។

19 ក្នុងន័យនេះ រឿងក្តីរវាង *Shamayev និង អ្នកផ្សេងទៀត តទល់នឹង ប្រទេសហ្សេអ័រហ្ស៊ី និង ប្រទេសរុស្ស៊ី* គឺជាការបញ្ជាក់បង្ហាញមួយ។ ជំនួសឱ្យដំណើរការនីតិវិធីក្នុងស្រុកដែលកំពុងតែបន្តតុលាការសិទ្ធិមនុស្សអឺរ៉ុបមានអំណាចផ្តួចផ្តើមបេសកកម្មស្វែងរកការពិតរបស់ខ្លួន។ តុលាការនេះបានរកឃើញថា "បេសកកម្មរបស់ខ្លួនមិនមែនជំនួសឱ្យការគ្រប់គ្រងក្នុងស្រុក ដោយការគ្រប់គ្រងរបស់អឺរ៉ុប ដែលបានបង្ហាញណែនាំដោយអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុបនោះទេ ប៉ុន្តែ មានតម្លៃចំពោះវិធានការផ្នែកនីតិវិធី នៅក្នុងបរិបទនៃការគ្រប់គ្រងនោះ។ តាមរយៈប្រព័ន្ធអនុវត្តន៍សិទ្ធិរួមដែលអនុសញ្ញាអឺរ៉ុបបង្កើតឡើងស្របតាមគោលការណ៍នៃការបំពេញបន្ថែម (the principle of subsidiarity) ហើយអនុសញ្ញានេះពង្រឹងការការពារនៅថ្នាក់ជាតិ [...] ប៉ុន្តែ ក៏មិនបានកម្រិតចំពោះការការពារនោះដែរ [...]" [83]។

---

[79] Sørensen, ទំព័រ ៥៨៩; Amerasinghe, ទំព័រ ១៩៥-៧; Brownlie, ទំព័រ ៤៨១; Shelton, ទំព័រ ២៣។

[80] Velasquez Rodriguez តទល់នឹង Honduras, តុលាការសិទ្ធិមនុស្សអន្តរសហរដ្ឋអាមេរិក (Inter-Am.Ct.H.R.) (1988) (Ser. C) លេខ ៤ កថាខណ្ឌ ៦៨ ។

[81] Isayeva តទល់នឹង ប្រទេសរុស្ស៊ី, (2005) 41 E.H.R.R. ទំព័រ ៣៨ កថាខណ្ឌ ១៥៣។

[82] D. Shelton, ដំណោះស្រាយតាមផ្លូវច្បាប់សិទ្ធិមនុស្សអន្តរជាតិ, (១៩៩៩) (Oxford, New York) (Oxford University Press), ទំព័រ ២៥ ។

[83] រឿងក្តីរវាង Shamayev និង អ្នកផ្សេងទៀត តទល់នឹង ប្រទេសហ្សេអ័រហ្ស៊ី និង ប្រទេសរុស្ស៊ី កថាខណ្ឌ ៥០០ ។

## ឆ. ការជ្រៀតជ្រែកដល់ការចាត់ចែងយុត្តិធម៌

20 វិធាន ៣៥ នៃវិធានផ្ទៃក្នុងផ្តល់អំណាចឲ្យ អ.វ.ត.ក "ដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច នូវជនណាម្នាក់ ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដដល់ការចាត់ចែងយុត្តិធម៌"។[84] ជាពិសេស "នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ មានហេតុផលជឿថា បុគ្គលណាម្នាក់ អាចធ្លាប់បានប្រព្រឹត្ត [ការជ្រៀតជ្រែកបែបនេះ] នោះសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាច (ក) ចាត់ការជាមួយបញ្ហានេះជាបន្ទាន់ (ខ) ដឹកនាំការស៊ើបសួរបន្ថែមដើម្បីឲ្យដឹងប្រាកដ ថាតើមាន មូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី ឬ (គ) បញ្ជូនបញ្ហានេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ ព្រះរាជាណាចក្រកម្ពុជា ឬអង្គការសហប្រជាជាតិ[85]។

## V. ឧត្តរណ៍[86]

## ក. បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន

21 អនុលោមតាមវិធាន ៦៣(៧) និង ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន។ បន្ថែមលើនេះទៅទៀត បណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់នៅក្នុងក្របខ័ណ្ឌពេលវេលាដែលកំណត់ដោយ វិធានផ្ទៃក្នុង ៧៥(៣)។

## ខ. ក.ស.ច.ស មានសិទ្ធិអំណាចជាប់មកជាមួយ ដើម្បីផ្តល់ដំណោះស្រាយដែលបានស្នើសុំ

22 យុត្តាធិការរបស់ ក.ស.ច.ស គឺមិនត្រូវបានកម្រិតត្រឹមតែដីកាសម្រេចដែលស្នើសុំនេះទេ។ ដូច ដែលបានលើកឡើងខាងលើ គ្រប់តុលាការទាំងអស់មានអំណាចជាប់មកជាមួយ ដើម្បីធានាឲ្យមាន សុច្ចរិតភាពនៃដំណើរការនីតិវិធីរបស់ខ្លួន។ យោងតាមទ្រឹស្តីដែលត្រូវបានគេដឹងឮយ៉ាងច្បាស់នោះគឺ អំពើទាំងឡាយណាដែលគំរាមកំហែងបង្កជាឧបសគ្គ ជ្រៀតជ្រែក ឬសម្របសម្រួលដល់កាតព្វកិច្ច

[84] វិធានផ្ទៃក្នុង ៣៥(១) ។

[85] វិធានផ្ទៃក្នុង ៣៥(២) (មានបញ្ជាក់បន្ថែម)។

[86] មេធាវីការពារសូមដាក់បញ្ចូលសារណា ដែលមាននៅក្នុងកថាខណ្ឌ ១៧ ដល់ ២១ នៃសំណើសុំនេះ។

ស៊ើបអង្កេតចំបងរបស់ ក.ស.ច.ស នោះការចោទប្រកាន់ពីឧក្រិដ្ឋកម្ម ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ ក.ស.ព គឺពិតជាការគំរាមកំហែងដល់ការចាត់ចែងយុត្តិធម៌ហើយ។ ហេតុដូច្នេះ វាស្ថិតនៅក្នុងរង្វង់អំណាចដែលមានជាប់មកជាមួយរបស់ ក.ស.ច.ស ក្នុងការបង្ការទោះជានៅក្រោយអង្គហេតុក្តី ឬជាបុព្វក្រ័យក្រី ដើម្បីជាវិធានការទប់ស្កាត់មួយ។

23 ការអនុវត្តអំណាចបែបនេះនៅក្នុងករណីនេះ គឺត្រូវបានគាំទ្រទាំងដោយសនិទានភាពឯកជន និងសាធារណៈ ដែលថ្លិតនៅក្រមទ្រឹស្តីនេះ។ ដោយសារថា វាជាប់ទាក់ទងទៅនឹងការកាត់សេចក្តីលើបទចោទសំខាន់ៗ (លក្ខណៈឯកជន) នោះរបៀបនៃកិច្ចស៊ើបសួរដែលបានធ្វើឡើង គឺពិតជាប៉ះពាល់ដល់គុណភាពនៃភស្តុតាងដែលបានប្រមូល។ ដូច្នេះ ក្រៅពីការ"មិនជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលបានរកឃើញតាមរយៈការស៊ើបអង្កេតសព្វថ្ងៃនេះទាល់តែសោះ"[87] នោះបញ្ហាពុករលួយ គឺពិតជាជាប់ជំពាក់ទៅនឹងការចោទប្រកាន់ដុំកំភួន ដូចដែលបានលើកឡើងលំអិតនៅក្នុងសំណើសុំនេះ[88]។ បន្ថែមលើនេះទៅទៀត តាមទស្សនៈវិស័យដែលអាចទាញជាធម្មនិយាមបាន (លក្ខណៈសាធារណៈ) អ.វ.ត.ក ត្រូវតែការពារខ្លួនឯងពីការរំលោភលើចំណាត់ការរឿងក្តី និងធានាថា យុត្តិធម៌ត្រូវបានចាត់ចែងឡើងក្នុងលក្ខណៈមួយជំរុញដល់ការអភិវឌ្ឍន៍ការអនុវត្តន៍ជាអន្តរជាតិ និង ក្នុងស្រុក។ លើសពីនេះទៅទៀត ដូចដែលយុត្តិសាស្ត្របានលើកឡើង ក.ស.ច.ស គួរផ្តល់នូវការពិចារណាខ្លះៗ ដល់ផលប្រយោជន៍ដ៏ទូលំទូលាយរបស់សហគមន៍ ដែលក្នុងនោះមានដូចជាការដើរតួជាឧទាហរណ៍ ទៅលើ សុច្ចរិតភាពឯករាជ្យភាព និងអព្យាក្រិត្យភាព ដល់សាធារណៈជនកម្ពុជា និងសហគមន៍ អ្នកច្បាប់។

24 ក.ស.ច.ស បានសម្រេចថា "ការទទួលយកនេះ គឺជាការប្រើប្រាស់អំណាចក្នុងផ្លូវខុស"[89]។ ដោយសារតែវាមិនត្រូវបានគាំទ្រដោយការអធិប្បាយណាមួយទៅលើច្បាប់ស្តីពីអំណាចដែលមានជាប់មកជាមួយ និងភ្ជាប់ទៅដោយភាពគ្មានតម្លៃ ដែលមិនមានការចំរើនលូតលាស់ទៅលើ "គោលការណ៍នីតិរដ្ឋ"[90] សេចក្តីសន្និដ្ឋាននេះមិនអើពើចំពោះលក្ខណៈមូលដ្ឋានរបស់តុលាការ និងធ្វើឲ្យ ក.ស.ច.ស.ចុះខ្សោយនៅក្នុងដំណើការក្តីនេះ។ ផ្ទុយស្រឡះទៅនឹងការវិភាគរបស់ ក.ស.ច.ស ការច្រានចោលនេះនាំឲ្យមានការ

---

[87] ដីកាសម្រេច កថាខណ្ឌ ១០ ។

[88] សូមអានសំណើសុំ, កថាខណ្ឌ ១៧ ដល់ ២១ ។

[89] ដីកាសម្រេច កថាខណ្ឌ ១១ ។

[90] ដីកាសម្រេច កថាខណ្ឌ ១១ (អក្សរពុម្ពទីក្នុងអត្ថបទដើម) ។

មិនអើពើដល់ការទទួលខុសត្រូវរបស់តុលាការដែលមិនអាចជៀសផុតបាន ក្នុងការចាត់ចែងយុត្តិធម៌ ។ ទស្សនៈប្រកបដោយឧត្តមគតិ គឺអាស្រ័យទៅលើសកម្មភាពអនុវត្តជាក់ស្តែងរបស់ចៅក្រមទាំងឡាយ ចំពោះការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពរបស់ពួកគេ។ ក្នុងករណីនេះ "នីតិរដ្ឋ" អាចនឹងត្រូវបានផ្តល់សេវាយ៉ាងប្រសើរបំផុតតាមរយៈ (i) ការទទួលស្គាល់របស់ ក.ស.ច.ស ថា ឥរិយាបទពិតប្រាកដរបស់ប្រធានរដ្ឋបាល អ.វ.ត.ក បានធ្វើឱ្យខូចខាតដល់សុច្ចរិតភាពរបស់សាលាក្តីនេះ និង(ii) ការសន្យារបស់ ក.ស.ច.ស ក្នុងការដោះស្រាយបញ្ហានេះ ដោយចាប់ផ្តើមពីការបញ្ជាឱ្យបង្ហាញឯកសារដែលបានស្នើសុំនេះ។

25 ជាការពិតហើយ ចៅក្រមមិនត្រូវធ្វើឱ្យហួស ឬរំលោភបំពានអំណាចរបស់ខ្លួននោះទេ ជាពិសេសអំណាចដែលមានជាប់មកជាមួយនេះតែម្តង។ ដូចគ្នានេះដែរ ចៅក្រមមិនគួរពឹងអាស្រ័យទៅលើទស្សនៈនៃការមិនបំពេញកិច្ចការតុលាការ ដើម្បីបិទបាំងខ្លួនពីបញ្ហានយោបាយដ៏គួរឱ្យរសើបនោះទេ។ ប៉ុន្តែ ដោយការមិនមានឱកាស វាចាំបាច់ត្រូវដោះស្រាយបញ្ហាស្មុកស្មាញបែបនេះ ក្នុងពេលណាមួយ ។ សម្រាប់ហេតុផលជាក់ស្តែងដែលបានលើកឡើងនៅក្នុងសំណើសុំនេះ និងដែលកាន់តែត្រូវបានធ្វើឱ្យរីកចម្រើនដូចមានខាងក្រោម នេះគឺជាពេលវេលាមួយក្នុងចំណោមពេលវេលាទាំងនោះ។ ហេតុផល "គ្រប់គ្រាន់"[91] នៅក្នុងករណីនេះ គឺគ្មានអ្វីក្រៅពីការចាត់ចែងយុត្តិធម៌ឱ្យបានត្រឹមត្រូវនៅក្នុង អ.វ.ត.ក នោះទេ ដូចលោក Jacques Verges បានលើកឡើងថ្មីៗនេះថា (ការរំលើកពីច្បាប់របស់ចក្រភពអង់គ្លេស ដែលបានលើកឡើងខាងលើ) អំពើពុករលួយធ្វើឱ្យប៉ះពាល់ដល់ "កិត្តិយស"របស់សាលាក្តីនេះជាស្ថាប័ន។[92] យ៉ាងហោចណាស់ក៏ ក.ស.ច.ស ហាក់បានយល់ព្រមចំពោះបញ្ហានេះដែរ[93]។

## គ. សំណើនេះ ត្រូវបានបង្ហាញហេតុផលពិតៗ គ្រប់គ្រាន់ សម្រាប់ការស្វែងរកដំណោះស្រាយ

---

[91] ដីកាសម្រេច, កថាខណ្ឌ ១១ ។

[92] សូមមើលប្រតិចារិតសវនាការលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន អ.ប.ជ ១៤ និង អ.ប.ជ ១៥ ថ្ងៃទី ៣ មេសា ២០០៨ ។ ("ខ្ញុំមិនប្រុងប្រយ័ត្នច្រើនជាងលោក និង អ្នកស្រីចៅក្រមខ្លួនឯងនោះទេ") ។

[93] សូមមើល ដីកាសម្រេច កថាខណ្ឌ ១២ (តាមពិត សហចៅក្រមស៊ើបអង្កេតត្រូវតែធានាថា ដំណើរការសរនីតិវិធីដែលកំពុងបន្តគឺមិនអាចមានកំហុស")។

26 ក.ស.ច.ស បានស្និដ្ឋានថា "គ្មានអ្វីដែលអាចបញ្ជាក់បានអំពីអត្ថិភាពនៃទង្វើបែបនេះទេ។ សំណើសុំនោះគ្រាន់តែលើកឡើងអំពីការប្រមើលឃើញ អំពីផលវិបាកដ៏អាក្រក់ជាយថាហេតុមួយ ប្រសិនបើមានអំពើពុករលួយគ្រប់រូបភាពកើតឡើងចំពោះដំណើរការនៃនីតិវិធីតុលាការតែប៉ុណ្ណោះ"។[94] ការវាយតម្លៃនេះ គឺមិនត្រូវចំនុចនេះទេ។ ក្នុងខណៈមេធាវីការពារយល់ស្របជាស្រេចថា ក្នុងដំណាក់កាលនេះ គេមិនអាចរៀបរាប់ពីហេតុផលជាក់ស្តែងនៃអំពើពុករលួយជាប្រព័ន្ធ ដែលកើតឡើងជាបន្តបន្ទាប់ ឬកំណត់អត្តសញ្ញាណរបស់អ្នកប្រព្រឹត្តខុសទាំងអស់បានទេ។ ការខ្វះភាពច្បាស់លាស់បែបនេះមិនធ្វើឱ្យខូចខាតដល់សំណើសុំនេះ ដែលជាសំណើសុំ*ព័ត៌មាន*នោះទេ។

27 ដូចដែលបានពន្យល់ពីមុនរួចមកហើយ ភស្តុតាងប្រឡាក់ប្រឡូកមានសក្តានុពលធ្វើឱ្យអន្តរាយដល់សុច្ចរិតភាពនៃកិច្ចការរបស់ ក.ស.ច.ស រហូតមកដល់សព្វថ្ងៃនេះ។[95] ប្រសិនបើក្រោយមកត្រូវបានរកឃើញថាបុគ្គលិកសំខាន់ៗបានជាប់ពាក់ព័ន្ធនៅក្នុងប្រភេទនៃឥរិយាបទមិនត្រឹមត្រូវ ដែលបានលើកឡើងនៅក្នុងសំណើនេះ ដែលជាលទ្ធផលនៃការចូលរួមរបស់ពួកគេ នៅក្នុងផែនការពុករលួយដែលបានចោទឡើងនេះ នោះកិច្ចស៊ើបសួរទាំងមូលត្រូវបានសម្របសម្រួល ហើយចុងក្រោយ មេធាវីការពារអាចត្រូវបានតម្រូវឱ្យស្នើសុំ ក.ស.ច.ស តម្កល់រឿងមិនចាត់ការ[96]។

28 ពិតណាស់ហើយ ដោយសារតែការព្រួយបារម្ភយ៉ាងខ្លាំងបែបនេះ នោះវាចាំបាច់ត្រូវរង់ចាំ "សកម្មភាពបញ្ជាក់អះអាង"[97] ពីការជ្រៀតជ្រែកដើម្បីធានាឱ្យមានវិធានការដ៏មានកម្រិតមួយចំនួនដែលបានស្នើសុំនៅក្នុងសំណើសុំនេះ។ យោងតាមភស្តុតាងដ៏ច្រើនលើសលប់ ដែលបានដាក់ជូនរហូតមកដល់សព្វថ្ងៃនេះ ដែលបានលើកឡើងដោយមិនមានអ្វីគួរឱ្យសង្ស័យពីប្រព័ន្ធពុករលួយជាស្ថាប័ននៅក្នុងសាលាក្តីនេះ ដែលបានរៀបចំឡើងដោយ ស៊ាន វិសុទ្ធ និងការព្រួយបារម្ភដែលបានរៀបរាប់នៅក្នុងកថាខណ្ឌមុនៗ បានស្នើសុំឱ្យមានការដាក់ចេញនូវសកម្មភាពឆាប់រហ័យ ដើម្បីវាយតម្លៃឱ្យបានត្រឹមត្រូវពីស្ថានភាពកិច្ចការសព្វថ្ងៃ និងពីមុនៗ នៅក្នុងការិយាល័យរដ្ឋបាល។ លទ្ធភាពចាក់ស្រេះ បែបនេះអាចជាការស្មានៗ។ តែនេះគឺដោយសារតែ សារជាតិ និងវិសាលភាពនៃអំពើពុករលួយត្រូវបានលាក់កំបាំងដោយមិនចាំបាច់

94 ដីកាសម្រេច, កថាខណ្ឌ ១២ ។

95 សូមមើលសំណើសុំ, កថាខណ្ឌ ១៨-២១។

96 សូមមើលកថាខណ្ឌ ១៣-១៥ ខាងលើ។

97 សំណើសុំ, កថាខណ្ឌ ១២។

ដោយ អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជាពីមេធាវីការពារ។ ដោយការចេញសេចក្ដីសម្រេចឲ្យបង្ហាញពីឯកសារនេះ នៅក្នុងពេលវេលាដំបូងៗតាមដែលអាចធ្វើទៅបាន ក.ស.ច.ស អាចបន្ធូរបន្ថយ ឬយ៉ាងហោចណាស់ អាចសម្រាលដល់ស្ថានភាពយ៉ាងដ៏វិនាសអន្តរាយនេះបានដែរ។

29 បន្ថែមពីលើនេះ ដូចដែលបានលើកឡើងពីខាងលើ និងនៅក្នុងសំណើនេះ ចៅក្រម និង មន្ត្រីជាន់ខ្ពស់ដទៃទៀតរបស់តុលាការ ត្រូវតែបានគេមើលឃើញថា បំពេញភារកិច្ចដោយឯករាជ្យ និង អនាគតិ។ ទោះបីជាគ្មានភស្តុតាងពិតប្រាកដនៅដំណាក់កាលនេះដែលថា សិទ្ធិរបស់ជនជាប់ចោទត្រូវបានរំលោភបំពានក៏ដោយ ក៏មានការចោទប្រកាន់ដែលត្រូវបានចងក្រងជាឯកសារយ៉ាងល្អ ព្រមជាមួយការធ្វើអត្ថាធិប្បាយរបស់លោក ហ៊ុន សែន នាពេលថ្មីៗនេះ[98] ក៏អាចគ្រប់គ្រាន់ ដើម្បីសន្និដ្ឋានអំពីកង្វះខាតនូវឯករាជ្យភាពរបស់តួអង្គសំខាន់ៗនៅ អ.វ.ត.ក ដែរ។ អាស្រ័យហេតុនេះ មេធាវីការពារគួរតែអាចពឹងពាក់ ក.ស.ច.ស ដើម្បីជួយដល់ការប្រមូលភស្តុតាងដែលអាចឈានទៅរកដំណោះស្រាយលើបញ្ហាដ៏លំបាកនេះ

30 និយាយឲ្យសាមញ្ញទៅ វិធីសាស្ត្រប្រមូលភស្តុតាងដែលអនុវត្តដោយ ក.ស.ច.ស មានលក្ខណៈតឹងរឹងពេក ព្រមទាំងមានភាពអកម្មផងដែរ។ មេធាវីការពារបានបង្ហាញនូវភស្តុតាងគ្រប់គ្រាន់ ដើម្បីសន្និដ្ឋានថាការគំរាមកំហែងដោយអំពើពុករលួយ គឺជាក់ស្ដែង ហើយហាយនិភ័យមានទំហំធំធេង ហើយផលវិបាកនឹងអាក្រក់ខ្លាំង ប្រសិនបើគ្មានដំណោះស្រាយនោះ។ ពុំមានមូលហេតុថា ហេតុអ្វីបានជា ក.ស.ច.ស ត្រូវជំទាស់ដល់មេធាវីការពារក្នុងការជីកឆ្កឹះឆ្កៀលរុករកការប្រព្រឹត្តខុសដែលគំរាមកំហែងបង្កអន្តរាយដល់ដំណើរការនីតិវិធី តាមរយៈការដាក់បន្ទុកនៃការបង្ហាញភស្តុតាងកម្រិតខ្ពស់ ដែលមិនចាំបាច់ ជាពិសេស បដិសេធលើសំណើសុំលាតត្រដាងព័ត៌មាននោះ។

## ឃ. វាជាការឥតប្រយោជន៍ក្នុងការរង់ចាំដំណោះស្រាយលើបញ្ហានេះ ដោយរាជរដ្ឋាភិបាលកម្ពុជា និង/ឬ អង្គការសហប្រជាជាតិ

31 ក.ស.ច.ស សន្និដ្ឋានថា សំណើសុំ "បំពេញកិច្ចស៊ើបសួររដ្ឋបាលទៅលើបញ្ហានេះ គឺជារឿងឥតប្រយោជន៍ ព្រោះថាទាំងអាជ្ញាធរកម្ពុជា និងអង្គការសហប្រជាជាតិ គឺជាអ្នកមានសមត្ថកិច្ចលើបញ្ហានេះ

---

[98] សូមមើល កថាខណ្ឌ ៥(១) ខាងលើ ។

ហើយមានព័ត៌មានគ្រប់គ្រាន់ដែលបានលើកឡើងក្នុងសំណើនេះ[99]។ ប៉ុន្តែ អកប្បកិរិយារបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងអំឡុងពេលប៉ុន្មានខែនេះ ដែលបានលើកឡើងនៅក្នុងសំណើនេះ និងលើឡើងពីខាងលើ គួរតែបានបញ្ជាក់យ៉ាងច្បាស់ទៅអ្នកសង្កេតការឥតលំអៀងថា ទាំងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ពុំមានចេតនាផ្តល់ឲ្យមេធាវីការពារក្តីនូវព័ត៌មានដែលខ្លួនចង់បាន (ចាំបាច់)។ បន្ថែមពីលើនេះ ដោយសារតែការលាតត្រដាងនៃគ្រោងការដែលបានចោទប្រកាន់ វាទំនងជាបង្ខូចកិត្តិយស់ដល់មន្ត្រីជាន់ខ្ពស់គណបក្សប្រជាជនកម្ពុជា និង ចំអកឡកឡឺដល់អង្គការសហប្រជាជាតិ ដែលស្ថាប័នទាំពីរមិនមានភាពលំអៀងដែលតម្រូវ ដើម្បីដោះស្រាយបញ្ហានេះឡើយ ។

32 ដូចដែលបានលើកឡើងដោយយុត្តិសាស្ត្រខាងលើ ក.ស.ច.ស មិនត្រូវវាយតម្លៃតែស្ថានការនោះទេ ប៉ុន្តែត្រូវពិចារណាឲ្យបានត្រឹមត្រូវលើបរិបទទាំងមូល ជាពិសេស គឺថាមានការពន្យារពេលមិនសមហេតុផលនៅក្នុងការដោះស្រាយសំណើរបស់មេធាវីការពារពីសំណាក់អង្គការសហប្រជាជាតិ និងការដែលថាអំពើពុករលួយដែលត្រូវបានអត់ឱននេះ (តាមពិតត្រូវបានជំរុញទឹកចិត្ត) ដោយរាជរដ្ឋាភិបាលកម្ពុជា។ កត្តាទាំងអស់នេះ បានរាំងមេធាវីការពារពីការទទួលបាននូវព័ត៌មានដែលបានស្វែងរក ហើយបញ្ហានេះត្រូវតែបានគេមើលឃើញថា “ជាឧបសគ្គដល់ដំណើរការត្រឹមត្រូវរបស់ប្រព័ន្ធរដ្ឋបាលតុលាការ”[100]។ ប្រវត្តិនីតិវិធីបង្ហាញឲ្យឃើញថា ការពឹងផ្អែកបន្តទៅទៀតទៅលើ “អាជ្ញាធរកម្ពុជា និង អង្គការសហប្រជាជាតិ”[101] នឹងជាការឥតប្រយោជន៍។

33 ស្ថិតនៅក្រោមកាលៈទេសៈបែបនេះ មេធាវីការពារបានធ្វើអ្វីៗគ្រប់បែបយ៉ាងដែលខ្លួនអាចធ្វើបាន ដើម្បីទទួលបានព័ត៌មានពាក់ព័ន្ធ។ បន្ទាប់ពីសំណើលើកដំបូងទៅអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជាត្រូវបានបដិសេធ មេធាវីការពារបានស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់នៅក្នុងប្រព័ន្ធតុលាការជាតិ។ នៅពេលកិច្ចប្រឹងប្រែងនេះមិនមានប្រសិទ្ធិភាព កិច្ចប្រឹងប្រែងបន្តទៀតត្រូវបានធ្វើឡើងនៅអង្គការសហប្រជាជាតិ ប៉ុន្តែនៅតែពុំទទួលបានផ្លែផ្កាដដែល។ ទាក់ទងនឹងកិច្ចប្រឹងប្រែងនេះ

---

[99] ដីកាសម្រេច កថាខណ្ឌ ១៣។

[100] សូមមើល កថាខណ្ឌ ១៨ ខាងលើ ។

[101] ដីកាសម្រេច កថាខណ្ឌ ១៣ ។

មេធាវីការពារពិតជាបានប្រើប្រាស់នូវ“ដំណោះស្រាយតាមប្រព័ន្ធច្បាប់ជាតិ”អស់ពីលទ្ធភាព មុនពេលបញ្ជូនបញ្ហាទៅអាជ្ញាធរតុលាការរបស់ អ.វ.ត.ក ជាទីកន្លែងដែលបញ្ចប់ការផ្លាស់ប្តូរការទទួលខុសត្រូវតាមការអង្កេតការដ៏ឆ្លាតវៃរបស់លោកចៅក្រម Justice Bernard[102]។

34 បន្ថែមពីលើនេះ គ្មានអ្វីអាចបញ្ឈប់ ក.ស.ច.ស ពីការស្នើសុំការស៊ើបសួរពិសេសទៅលើការចោទប្រកាន់ពីអំពើពុករលួយនោះទេ។ នៅពេលដែល ក.ស.ច.ស មានហេតុផលជឿជាក់ថា បុគ្គលណាម្នាក់ “អាចធ្លាប់” ជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ ក.ស.ច.ស អាច “ដឹកនាំការស៊ើបសួរបន្ថែមដើម្បីឲ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី ដែរឬយ៉ាងណា”[103] អ្វីដែលត្រូវការនោះ គឺ “ហេតុផលជឿជាក់”ថា មានការប្រព្រឹត្តអំពើបែបនោះមែន[104]។ ដោយពិចារណាទៅលើការបញ្ចេញឲ្យដឹងជាច្រើនដោយបុគ្គលិកបុគ្គលិក ព្រមទាំងអាកប្បកិរិយារបស់អង្គការសហប្រជាជាតិ និង រដ្ឋាភិបាលកម្ពុជា នោះគេពិបាកនឹងជំទាស់ថា មិនមានការយល់ខុសយ៉ាងធ្ងន់ធ្ងរនៅក្នុងការិយាល័យរដ្ឋបាលនោះឡើយ។ សន្មត់ថា អង្គការសហប្រជាជាតិ និង/ឬរដ្ឋាភិបាលកម្ពុជា កំពុងធ្វើចំណាត់ការយ៉ាងលឿន ប្រកបដោយចេតនាសុច្ចរិតក៏ដោយ ក៏អំណាចស៊ើបសួររបស់ ក.ស.ច.ស ទៅលើការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការយ៉ាងធ្ងន់ធ្ងរ នឹងមិនត្រូវបានកាត់បន្ថយ ដោយស្ថាប័នដទៃទៀតដែលហាក់ដូចជាកំពុងដោះស្រាយបញ្ហានេះដែរ[105] ។

## V. សេចក្តីសន្និដ្ឋាន

35 អាស្រ័យដោយហេតុផលទាំងអស់ដែលបានលើកឡើងនៅទីនេះ មេធាវីការពារសូមលើកឡើងថា ការបដិសេធសំណើសុំដោយ ក.ស.ច.ស គឺមិនត្រឹមត្រូវតាមអង្គច្បាប់ គោលនយោបាយសាធារណៈ និង សុភនិច្ឆ័យនោះទេ។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះគប្បីមោឃៈភាពដីកាសម្រេច និង សូមមេត្តាផ្តល់ដំណោះស្រាយដែលបានស្នើសុំនៅកថាខណ្ឌ ២២ នៃសំណើនេះ។ បន្ថែមពីលើនេះ

[102] សូមមើល កថាខណ្ឌ ៩ ខាងលើ ។

[103] វិធាន ៣៥(២) ។

[104] ដូចខាងលើ ។

[105] សូមមើលកថាខណ្ឌ ១៩ ខាងលើ ។

សារណាបណ្តឹងឧទ្ធរណ៍នេះមិនបានលើកឡើងពីសម្ភារៈសម្ងាត់ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះគប្បីចាត់ចំណាត់ថ្នាក់ឯកសារនេះ ជាឯកសារសាធារណៈ។ ជាចុងបញ្ចប់ មេធាវីការពារស្នើសុំនូវសវនាការដេញដោលជាសាធារណៈ នៅពេលឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។

សូមអង្គបុរេជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណនេះដោយក្តីគោរពុំ ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០០៩

សុន អរុណ

Michiel PESTMAN និង Victor KOPPE

P.P.

សហមេធាវីមេធាវីរបស់លោក នួន ជា